ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២២ លេខ១៣ ត្រីមាសទី០១ ឆ្នាំ២០២២

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៧-២-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០២២២/១៥២ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍មុនពេលកំណត់លោកឧត្តមសេនីយ៍ត្រី **ជីង សៀង** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជានៃក្រសួងមហាផ្ទៃ | ១៤៨៩ |
| ១៧-២-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០២២២/១៥៣ ស្តីពី ការតែងតាំងមុខតំណែង ជារដ្ឋលេខាធិការ ជាអនុរដ្ឋលេខាធិការ និងជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន នៃក្រសួងធនធានទឹក និងឧតុនិយម និងជាអគ្គលេខាធិការរង នៃអាជ្ញាធរទន្លេសាប | ១៤៩០ |
| ១៧-២-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០២២២/១៥៤ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ដល់ឧត្តមសេនីយ៍ទោ **សុខ ហេង** នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ | ១៤៩១ |
| ១៧-២-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០២២២/១៥៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៦ រូប | ១៤៩២ |
| ១៧-២-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០២២២/១៥៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះមន្ត្រីរាជការ ៧រូប | ១៤៩៣ |
| ១៨-២-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០២២២/១៥៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ឧបាសក និងឧបាសិកា ចំនួន ៤០រូប | ១៤៩៤ |
| ១៩-២-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០២២២/១៥៨ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ជាកិច្ចបច្ឆាមរណៈ ចំពោះឧត្តមសេនីយ៍ទោ **អុំ ករុណា** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌនគរបាលជាតិកម្ពុជា ដែលបានទទួលមរណភាព | ១៤៩៦ |
| ១៩-២-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០២២២/១៥៩ ស្តីពី ការបន្ថយឋានន្តរស័ក្តិលោក **រស់ សុធា** នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ | ១៤៩៧ |
| ១៩-២-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០២២២/១៦០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសដល់មន្ត្រីរាជការនៃក្រសួងសុខាភិបាល ៨រូប | ១៤៩៨ |
| ២១-២-២០២២ | -ព្រះរាជក្រឹត្យ នស/រកត/០២២២/១៦១ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោក **ម៉ៅ សុខ** ដែលបានទទួលមរណភាព | ១៤៩៩ |

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


| | | |
|---|---|---|
| ២៤-២-២០២២ | -អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្ដីពី ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ | ១៥០០ |
| ២៨-២-២០២២ | -អនុក្រឹត្យលេខ ៤៣ អនក្រ.បក ស្ដីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១៥០៩ |
| ២-៣-២០២២ | -អនុក្រឹត្យលេខ ៤៥ អនក្រ.បក ស្ដីពី ការកាត់ឆ្វៀលដីទំហំ ៣ហិកតា ៣៧អា ស្ថិតនៅភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ចេញពីដែនគម្របព្រៃឈើឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលកាន់កាប់ជាក់ស្ដែង | ១៥៤៥ |
| ៩-៣-២០២២ | -អនុក្រឹត្យលេខ ១៣៤ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ | ១៥៤៩ |
| ៩-៣-២០២២ | -អនុក្រឹត្យលេខ ១៣៥ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ១៥៥០ |
| ៩-៣-២០២២ | -អនុក្រឹត្យលេខ ១៣៦ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ | ១៥៥៣ |
| ៩-៣-២០២២ | -អនុក្រឹត្យលេខ ១៣៧ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ | ១៥៥៤ |
| ៩-៣-២០២២ | -អនុក្រឹត្យលេខ ១៣៨ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ១៥៥៦ |
| ៩-៣-២០២២ | -អនុក្រឹត្យលេខ ១៣៩ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ១៥៥៨ |
| ៩-៣-២០២២ | -អនុក្រឹត្យលេខ ១៤០ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ១៥៦៣ |
| ៩-៣-២០២២ | -អនុក្រឹត្យលេខ ១៤១ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ | ១៥៦៦ |
| ៩-៣-២០២២ | -អនុក្រឹត្យលេខ ១៤២ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា | ១៥៦៨ |
| ៩-៣-២០២២ | -អនុក្រឹត្យលេខ ១៤៣ អនក្រ.តត ស្ដីពី ការតម្លើងថ្នាក់មន្ត្រីរាជការ | ១៥៧២ |
| ៩-៣-២០២២ | -អនុក្រឹត្យលេខ ១៤៤ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ១៥៧៤ |
| ១០-៣-២០២២ | -អនុក្រឹត្យលេខ ១៤៥ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ១៥៧៧ |
| ១០-៣-២០២២ | -អនុក្រឹត្យលេខ ១៤៦ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ១៥៨១ |
| ១០-៣-២០២២ | -អនុក្រឹត្យលេខ ១៤៧ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ | ១៥៨៣ |


### ២~សេចក្តីសម្រេច


| | | |
|---|---|---|
| ១-៤-២០២២ | -សេចក្តីសម្រេចលេខ ២១ សសរ ស្ដីពី ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងចាត់ចែងចំណូល ដែលបានមកពីការផ្ទេរផ្ទៃដីចំនួន ២ ទីតាំង សរុបទំហំ ៣៦ ហិកតា ១៦ អា ៣៤ សង់ទីអា ស្ថិតនៅសង្កាត់គោករកា និងសង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ សម្រាប់ចំណាយលើការងារសាងសង់មណ្ឌលព្យាបាលជំងឺកូវីដ-១៩ តេជោសន្តិភាព រាជធានីភ្នំពេញ | ១៥៨៥ |

# III~ការងារបណ្តាក្រសួង

## ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


| | | |
|---|---|---|
| ១៥-៣-២០២២ | -ប្រកាសលេខ ១១៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីភែល (ខេមបូឌា) បង្កើតរោងចក្រ ផលិតរូបពីរោមសត្វ និងស្បែកសត្វ, កែច្នៃរោមសត្វ និងស្បែកជាប់រោមសត្វ | ១៥៨៧ |
| ១៦-៣-២០២២ | -ប្រកាសលេខ ១១៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេមបូឌាន សឹង្ហហុង ផេកខេកជីង ឯ.ក បង្កើតរោងចក្រ ផលិតកេសកាតុង និងផលិតផលប្លាស្ទិក | ១៥៩០ |


## ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


| | | |
|---|---|---|
| ២៣-៣-២០២១ | -ប្រកាសលេខ ០៣៥៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៣៥៦ រថ.អប្រក.លអ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២១ | ១៥៩៣ |
| ២២-៣-២០២២ | -ប្រកាសលេខ ០១៨៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៨៦ រថ.អប្រក.លអ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២២ | ១៥៩៧ |
| ២៣-៣-២០២២ | -ប្រកាសលេខ ០១៩២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០១៩២ រថ.អប្រក.លអ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២២ | ១៦០១ |
| ៣១-៣-២០២២ | -ប្រកាសលេខ ០២០២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០២០២ រថ.អប្រក.លអ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២២ | ១៦០៥ |
| ៣១-៣-២០២២ | -ប្រកាសលេខ ០២០៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០២០៤ រថ.អប្រក.លអ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២២ | ១៦០៩ |

# ព្រះរាជក្រឹត្យ

នស/រកត/០២២២/ ១៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ក្រឹត្យលេខ ១០ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលប្រជាជនកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១០/៤៦៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## ត្រាស់បង្គាប់

**មាត្រា ១** : ដាក់ឱ្យចូលនិវត្តន៍មុនពេលកំណត់លោកឧត្តមសេនីយ៍ត្រី **ជីង សៀង** អត្តលេខ ៦៣១៥១ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជានៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តម សីហមុនី

ការស.២២០២.១៥៥

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០២២

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០២២២/១៥៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងមុខតំណែង ជារដ្ឋលេខាធិការ ជាអនុរដ្ឋលេខាធិការ និង ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន នៃក្រសួងធនធានទឹក និងឧតុនិយម និង ជាអគ្គលេខាធិការរង នៃអាជ្ញាធរទន្លេសាបៈ

១- ឯកឧត្តម **ចាន់ ស៊ីណាត** ជារដ្ឋលេខាធិការ
២- ឯកឧត្តម **ស៊ិន ទិសិទ្ធ** ជាអនុរដ្ឋលេខាធិការ
៣- ឯកឧត្តម **ហ៊ួច ស៊ុនថាន** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន
៤- ឯកឧត្តម **ជា សុខនី** ជាអគ្គលេខាធិការរងអាជ្ញាធរទន្លេសាប មានឋានៈស្មើ អគ្គនាយក។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

សីហមុនី

ពរស.២២០២.១៥៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០២២២/១៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

### ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ដល់ ឧត្តមសេនីយ៍ទោ **សុខ ហេង** អត្តលេខ ០១១៥២២ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ពរស.២២០២.១៥៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២២/១៥៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ :**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | **រ័ត្ន** | **សេរី** | អត្តលេខ ២៣២២៦១ |
| ២-ឧត្តមសេនីយ៍ត្រី | **នួន** | **ទិសុទ្ធ** | អត្តលេខ ១៦៨០៥៨ |
| ៣-ឧត្តមសេនីយ៍ត្រី | **ពៅ** | **សំណាង** | អត្តលេខ ០១១៧៦៨ |
| ៤-ឧត្តមសេនីយ៍ត្រី | **ហាក់** | **ខួនឈាង** | អត្តលេខ ០១១៧៤៤ |

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី :**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **ហៀង** | **សុខហេង** | អត្តលេខ ០៥៤៩៤៩ |
| ២-វរសេនីយ៍ឯក | **ម៉េត** | **មករា** | អត្តលេខ ២៣២១២១ |

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

[illegible].២២០២.១៥៥

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២២/១៥៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះមន្ត្រីរាជការ ៧រូប ៖

ក- គ្រឿងឥស្សរិយយស **ជាតូបការ**

-ឯកឧត្តម សោម ពិសិដ្ឋ

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

-ឯកឧត្តម សុទ្ធ ពុទ្ធិម៉ានីន

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

១-លោក អ៊ីន គុងអាន ២-លោក បាន ប៊ុនហេង

ឃ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

-ឯកឧត្តម លុច្ស តារា

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

១-លោក ខូវ អៀហៃ ២-លោកស្រី ឆាយ ស្មើ

ពសព.២៤០២.១៥៩

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានបង្គាប់ក្រោមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០២២២/១៥៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- លោកជំទាវ **ផេង ពុទ្ធិតា គង់សោភ័ណ្ឌ**
២- លោកមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **ហ៊ីន ហេងគង់**
៣- លោកមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ឡូច សារុណា**

**ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- លោកជំទាវ **ផុង សុវណ្ណរឡើយ៍**
២- ឯកឧត្តម **ជា ហ្គារូដា**
៣- លោកស្រី **ផុង វណ្ណារ៉ា**
៤- លោកស្រី **ផុង វណ្ណារី**
៥- លោកស្រី **ផុង វណ្ណារ៉ុង**
៦- លោក **ឃិន ប៊ូរ័ត្ន**

**គ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :**

១- លោក **ជុន ជឹម**
២- លោក **យស់ សារ៉ាន់**
៣- លោក **ឌិន វណ្ណនី**

**ឃ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

១- លោកឧបាសិកា **លុយ ហឿង**
២- លោកឧបាសិកា **លី សុខចឹម**
៣- លោក **សរ សាវ**
៤- លោកឧបាសិកា **កែវ គាព**
៥- លោកឧបាសិកា **អ៊ី ចឹម**
៦- លោកឧបាសិកា **ទ៉ូច សន**
៧- លោកឧបាសិកា **ឈួន ម៉ៅ**
៨- លោកឧបាសក **សួត ហាវ**
៩- លោកឧបាសិកា **ម៉ោង សៀប**
១០- លោកឧបាសិកា **ពុយ សុខឡា**
១១- លោកឧបាសក **ឆេស យ៉ង់**
១២- លោកឧបាសក **អំ អុន**
១៣- លោកឧបាសក **ឆៃ ពៅ**
១៤- លោកឧបាសក **ពុត ម៉េត**
១៥- លោកឧបាសក **អ៊ំ ផុស**
១៦- លោក **ញ៉ៀម ស៊ីច័ន្ទ**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ង- មេដាយការងារ ថ្នាក់ មាស :

១- លោកឧបាសក ពិន រឹម
២- លោកឧបាសក ម៉ៃ ខុន
៣- លោកឧបាសក ផុន គិន
៤- លោកឧបាសក អែម អន
៥- លោកឧបាសក សួន សេម
៦- លោកឧបាសក សំ សុគ
៧- លោកឧបាសក អែម ស៊ឹម
៨- លោកឧបាសក ឡៀប ឆែន
៩- លោកឧបាសក យឹម ចិន
១០- លោកឧបាសក ថាច ឡាយ
១១- លោកឧបាសក សំ ស៊ីន
១២- លោកឧបាសក អាន គ្រឹល

នស.រកត.០២២២.១៦០

បានប្រថាប់ព្រះរាជលញ្ឆករហើយ

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២២

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ០០៣/២២ វរ. ចច
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២២
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/០២២២/ ១៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈ ចំពោះឧត្តមសេនីយ៍ទោ **អ៊ឺ ករុណា** អត្តលេខ ០៨៩៨៩ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា ដែលបានទទួលមរណភាព ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តម សីហមុនី

ការស.២៤០២.១៦១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**
បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសល្យបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០២២២/ ១៥៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បន្ថយឋានន្តរស័ក្តិ លោក **រស់ សុធា** អត្តលេខ ០១៥៦ ពីឋានន្តរស័ក្តិឧត្តមអគ្គានុរក្ស ថ្នាក់លេខ៣ មកជាឋានន្តរស័ក្តិវររអគ្គានុរក្ស ថ្នាក់លេខ១ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

៣៣៥.២២០២.១៦២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០២២២/ ១៦០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការនៃក្រសួងសុខាភិបាល ៨រូប៖

ក-គ្រឿងឥស្សរិយយស **ជាតូបការ**

លោកសាស្ត្រាចារ្យរង **លូ លីឃាង**

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

១- លោក Kim Kwang Wook

២- លោកសាស្ត្រាចារ្យ Suh Yousung

៣- លោក Hoh Jip

នរោត្តម សីហមុនី

ចរ.២២០២.១៦៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២២*

**នរោត្តម សីហមុនី**

បានបង្ហាញគ្រឿងគ្រាតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០២២២/ ១៦១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ជាកិច្ចបច្ឆាមរណៈ**

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

ចំពោះ

លោក **ម៉ៅ សុខ**
ដែលបានទទួលមរណភាព

ពរល.២២០២.១៦៤

**បានប្រទាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២២*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ...០០៤/២២...រ.ចច
រាជធានីភ្នំពេញ, ថ្ងៃទី ២១.... ខែ ..កុម្ភៈ....ឆ្នាំ ២០២២
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៤០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-** គោលបំណង

អនុក្រឹត្យនេះមានគោលបំណងផ្តល់ការលើកទឹកចិត្តពន្ធដារ ដើម្បីអភិវឌ្ឍវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីប្រភេទ សកម្មភាព និងលក្ខខណ្ឌនានា ដែលជាកម្មវត្ថុនៃការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩។

**មាត្រា២.-** វិសាលភាព

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះ÷

១.ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា (សរសេរកាត់ថា **ន.ម.ក.**) និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

២.មូលបត្ររដ្ឋ ដែលសំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុលដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល ដូចដែលបានបញ្ញត្តនៅក្នុងមាត្រា៣ នៃច្បាប់ស្តីពីមូលបត្ររដ្ឋ។



1

៣.អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ និង/ ឬ ទិញ-លក់មូលបត្រដ្ឋ មូលបត្រកម្មសិទ្ធិ និង/ ឬ មូល-បត្របំណុលដែលបានបោះផ្សាយលក់ជាសាធារណៈ និងបានចុះបញ្ជីនៅទីផ្សារមូលបត្រប្រតិស្រុត។ សម្រាប់គោលដៅនៃអនុក្រឹត្យនេះ អ្នកវិនិយោគសាធារណៈរួមបញ្ចូលទាំងអ្នកវិនិយោគនិវាសនជននិងអនិវាសនជន។

## ជំពូកទី២

## សកម្មភាព និងលក្ខខណ្ឌនៃការលើកទឹកចិត្តពន្ធដារ

**មាត្រា៣.-** ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបំពេញបែបបទជូនអគ្គនាយកដ្ឋានពន្ធដារតាមរយៈ **ន.ម.ក.** នៅរាល់មុនការិយបរិច្ឆេទបង់ពន្ធសម្រាប់ឆ្នាំសារពើពន្ធនីមួយៗដើម្បីទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលតាមលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ ក្នុងរយៈពេលនៃការទទួលបានការលើកទឹកចិត្តពន្ធដារ ដូចមានកំណត់ក្នុងកថាខណ្ឌទី២ នៃមាត្រា៣ នៃអនុក្រឹត្យនេះ។

ការលើកទឹកចិត្តពន្ធដារមានរយៈពេល ៣ (បី) ឆ្នាំ និងត្រូវគិតចាប់ផ្តើមពី÷

១-ដើមឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបានបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះ-ផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ដើមឆ្នាំជាប់ពន្ធនោះ។

២-ដើមឆ្នាំជាប់ពន្ធបន្ទាប់ពីឆ្នាំជាប់ពន្ធដែលមូលបត្រនោះត្រូវបោះផ្សាយលក់ជាសាធារណៈ ក្នុងករណីដែលការបោះផ្សាយលក់នោះធ្វើឡើងក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចុងឆ្នាំជាប់ពន្ធ។

៣-អំឡុងពេលណាមួយដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤.-** **លក្ខខណ្ឌដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល**

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល ត្រូវបានកំណត់អំពីលក្ខខណ្ឌដូចខាងក្រោម÷

១-ក្រុមហ៊ុន/ សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំលើសពី ២០ (ម្ភៃ) ភាគរយ នៃសិទ្ធិបោះឆ្នោត និង/ ឬ បោះផ្សាយមូលបត្របំណុលក្នុងទំហំលើសពី ២០(ម្ភៃ) ភាគរយ នៃទ្រព្យសកម្មសរុប និងមានឥណប្រតិទានយ៉ាងតិច ៧ (ប្រាំពីរ) ឆ្នាំ នឹងទទួលបាននូវការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណូលចំនួន ៥០ (ហាសិប) ភាគរយ នៃពន្ធលើប្រាក់ចំណូលត្រូវបង់។

២-ក្រុមហ៊ុន/ សហគ្រាសដែលបោះផ្សាយមូលបត្រកម្មសិទ្ធិក្នុងទំហំ ២០(ម្ភៃ) ភាគរយ ឬតិចជាង នៃសិទ្ធិបោះឆ្នោត និង/ ឬ បោះផ្សាយមូលបត្របំណុលក្នុងទំហំ ២០(ម្ភៃ) ភាគរយ ឬ តិចជាងនៃទ្រព្យសកម្មសរុបនឹងទទួលបាននូវការលើកទឹកចិត្តពន្ធតាមសមាមាត្រចុះដោយយក ២០,០០១ ជាគោល (ដូចមានក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ) ដែលក្នុងនោះ÷

- ការបោះផ្សាយមូលបត្រកម្មសិទ្ធិ÷ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រ មិនឱ្យលើសពី ២០(ម្ភៃ) ប៊ីលានរៀល។

- ការបោះផ្សាយមូលបត្របំណុល÷ ការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលតាមសមាមាត្រ មិនឱ្យលើសពី ៨ (ប្រាំបី) ប៊ីលានរៀល។

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលជាសាធារណៈ ដើម្បីទទួលបានហិរញ្ញប្បទានក្នុងគោលដៅនៃការអភិវឌ្ឍបៃតង និងប្រកបដោយចីរភាព ឬការអភិវឌ្ឍក្នុងវិស័យអាទិភាពណាមួយ នឹងទទួលបានការលើកទឹកចិត្តពន្ធដារពិសេសបន្ថែម តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥.- ការអនុគ្រោះបំណុលពន្ធចំពោះក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ**

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត ក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន ត្រូវទទួលបានការអនុគ្រោះបំណុលពន្ធដែលរួមបញ្ចូលពន្ធលើប្រាក់ចំណូលទាំងស្រុង ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ។ ការអនុគ្រោះបំណុលពន្ធទាំងស្រុងត្រូវអនុវត្តដូចខាងក្រោម÷

១- បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-3 ដល់ N-10 សម្រាប់ក្រុមហ៊ុន/ សហគ្រាសដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារគោល។

២- បំណុលពន្ធចាប់ពីកាលបរិច្ឆេទ N-2 ដល់ N-10 សម្រាប់សហគ្រាសធុនតូច និងមធ្យមដែលបានបំពេញលក្ខខណ្ឌក្នុងការចុះបញ្ជីនៅទីផ្សារកំណើន។ (ឆ្នាំ N គឺជាឆ្នាំដែលក្រុមហ៊ុន/ សហគ្រាសធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលជាសាធារណៈជាលើកដំបូង។)

ការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនតម្រូវឱ្យមានការធ្វើសវនកម្មពេញលេញជាមុនពីអគ្គនាយកដ្ឋានពន្ធដារនោះទេ។ សម្រាប់ការស្នើសុំបោះផ្សាយ ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈត្រូវផ្តល់ជូន **ន.ម.ក.** នូវវិញ្ញាបនបត្របញ្ជាក់កាតព្វកិច្ចពន្ធចេញ

ដោយអគ្គនាយកដ្ឋានពន្ធដារ ដែលជាលិខិតសម្រាប់បញ្ជាក់ពីការប្រកាស និងបង់ពន្ធជាប្រចាំដោយមិនទាន់រងការធ្វើសវនកម្មពីអគ្គនាយកដ្ឋានពន្ធដារ។

**មាត្រា៦.- ការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធនដល់អ្នកវិនិយោគមូលបត្រ**

អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយលើការប្រាក់ និង/ឬ ភាគលាភដែលបានមកពីការកាន់កាប់ និង/ឬ ការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល និងត្រូវបានលើកលែងពន្ធលើចំណេញមូលធន ចំពោះការទិញ និងការជួញដូរមូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលសម្រាប់រយៈពេល ៣(បី) ឆ្នាំ គិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

បុគ្គលជាភ្នាក់ងារកាត់ទុកដែលធ្វើការបើកការប្រាក់ និង/ឬ ភាគលាភត្រូវធ្វើការគណនាប្រាក់ពន្ធកាត់ទុកដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មុនការបើកប្រាក់ និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធកាត់ទុកជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០(ម្ភៃ) នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។

ការកំណត់អត្រាពន្ធលើការប្រាក់នៃមូលបត្ររដ្ឋ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧.- ក្រុមហ៊ុន/ សហគ្រាសដែលមិនត្រូវបានទទួលការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល**

ក្រុមហ៊ុន/ សហគ្រាសមិនត្រូវទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងមាត្រា៣ និងមាត្រា៥ នៃអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុននោះជាសហគ្រាសវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលកំពុងស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨.- ការបញ្ឈប់ និងការដកហូតការលើកទឹកចិត្តពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារអាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈ **ន.ម.ក.** ដើម្បីបញ្ឈប់ និងដកហូតការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងមាត្រា៣ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ ក្នុងករណីក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត÷

- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ និងបង់ប្រាក់ពន្ធ តាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។
- មិនបានដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធ និងបង់ប្រាក់ពន្ធតាមកាលកំណត់របស់រដ្ឋបាលសារពើពន្ធ។ លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ រួមមានតារាងតុល្យការ គណនីលទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ដោយមិនឱ្យហួសពីរយៈពេល ៣(បី) ខែ ក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។

- មិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើសវនកម្មលើបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ។

- មិនបានបង់ពន្ធអាករទាំងអស់ ពន្ធបន្ថែម និងការប្រាក់ ដែលបានកំណត់សម្រាប់រយៈពេលជាប់ពន្ធដែលបានធ្វើសវនកម្មរួចដោយរដ្ឋបាលសារពើពន្ធ។

- អគ្គនាយកដ្ឋានពន្ធដាររកឃើញថាក្រុមហ៊ុន/ សហគ្រាសមានចេតនាគេចវេះពន្ធ តាមរយៈការបោះផ្សាយមូលបត្រលើកដំបូងជាសាធារណៈ។

ក្នុងករណីក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះ មិនបានអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យមូលបត្រ **ន.ម.ក.** អាចស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបញ្ឈប់ការលើកទឹកចិត្តដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៣ និងការអនុគ្រោះបំណុលពន្ធដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ។

ក្រុមហ៊ុន/ សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតមិនត្រូវទទួលបាននូវការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងអនុក្រឹត្យនេះឡើយ ក្នុងករណីក្រុមហ៊ុន/-សហគ្រាសនោះបានដកខ្លួនចេញពីការចុះបញ្ជី ឬត្រូវបានដកពីការចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៩.**- ការលើកទឹកចិត្តពន្ធដារចំពោះក្រុមហ៊ុន/ សហគ្រាសដែលបានបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈរួច

ក្រុមហ៊ុន/ សហគ្រាសដែលទទួលបានការអនុញ្ញាតពី **ន.ម.ក.** ធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងដែលបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុតរួចហើយ តែមិនទាន់ទទួលបាននូវការលើកទឹកចិត្តពន្ធដារនោះ ត្រូវបានផ្តល់ការលើកទឹកចិត្តពន្ធដារដូចមានចែងក្នុងមាត្រា៣ នៃអនុក្រឹត្យនេះ។

**មាត្រា១០.**-ការជំនួស

បញ្ញត្តិទាំងឡាយដែលចេញឡើងស្របតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រនឹងត្រូវបន្តអនុវត្តអនុលោមតាមអនុក្រឹត្យនេះ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១.-** ការអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## នៃអនុក្រឹត្យលេខ ៥៥... អនក្រ.បក ចុះថ្ងៃទី២៤. ខែ[illegible]ឆ្នាំ ២០២២

## ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ

* * * *

## តារាងសមាមាត្រក្នុងការផ្តល់ការលើកទឹកចិត្តពន្ធដារ ដោយយកទំហំនៃការបោះផ្សាយ ២០,០០១* ជាគោល

| ល.រ | ទំហំបោះផ្សាយ | សមាមាត្រភាគរយនៃការលើកទឹកចិត្តទទួលបាន | ភាគរយនៃការលើកទឹកចិត្តលើប្រាក់ពន្ធត្រូវបង់ប្រចាំឆ្នាំ (ដូចក្នុងអនុក្រឹត្យ) |
|---|---|---|---|
| | A | B = A / 20.001% | C = B * 50% |
| 1 | ចាប់ពី 20.001% | 100.000% | 50.000% |
| 2 | 20.000% | 99.995% | 49.9975% |
| 3 | 19.500% | 97.495% | 48.748% |
| 4 | 19.000% | 94.995% | 47.498% |
| 5 | 18.500% | 92.495% | 46.248% |
| 6 | 18.000% | 89.996% | 44.998% |
| 7 | 17.500% | 87.496% | 43.748% |
| 8 | 17.000% | 84.996% | 42.498% |
| 9 | 16.500% | 82.496% | 41.248% |
| 10 | 16.000% | 79.996% | 39.998% |
| 11 | 15.500% | 77.496% | 38.748% |
| 12 | 15.000% | 74.996% | 37.498% |
| 13 | 14.500% | 72.496% | 36.248% |
| 14 | 14.000% | 69.997% | 34.998% |
| 15 | 13.500% | 67.497% | 33.748% |
| 16 | 13.000% | 64.997% | 32.498% |
| 17 | 12.500% | 62.497% | 31.248% |
| 18 | 12.000% | 59.997% | 29.999% |
| 19 | 11.500% | 57.497% | 28.749% |
| 20 | 11.000% | 54.997% | 27.499% |
| 21 | 10.500% | 52.497% | 26.249% |
| 22 | 10.000% | 49.998% | 24.999% |

| | | | |
|---|---|---|---|
| 23 | 9.500% | 47.498% | 23.749% |
| 24 | 9.000% | 44.998% | 22.499% |
| 25 | 8.500% | 42.498% | 21.249% |
| 26 | 8.000% | 39.998% | 19.999% |
| 27 | 7.500% | 37.498% | 18.749% |
| 28 | 7.000% | 34.998% | 17.499% |
| 29 | 6.500% | 32.498% | 16.249% |
| 30 | 6.000% | 29.999% | 14.999% |
| 31 | 5.500% | 27.499% | 13.749% |
| 32 | 5.000% | 24.999% | 12.499% |
| 33 | 4.500% | 22.499% | 11.249% |
| 34 | 4.000% | 19.999% | 10.000% |
| 35 | 3.500% | 17.499% | 8.750% |
| 36 | 3.000% | 14.999% | 7.500% |
| 37 | 2.500% | 12.499% | 6.250% |
| 38 | 2.000% | 10.000% | 5.000% |
| 39 | 1.500% | 7.500% | 3.750% |
| 40 | 1.000% | 5.000% | 2.500% |

សម្គាល់÷

$$\text{ភាគរយនៃការលើកទឹកចិត្តពន្ធលើប្រាក់ចំណូល} = \frac{\text{ទំហំបោះផ្សាយធៀបនឹងសិទ្ធិបោះឆ្នោតសរុប ឬទ្រព្យសកម្មសរុប}}{\text{ទំហំបោះផ្សាយគោល (20.001\%)}} \times 50\%$$

* សម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិ÷ ទំហំបោះផ្សាយត្រូវធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតសរុប។
* សម្រាប់ការបោះផ្សាយមូលបត្របំណុល÷ ទំហំបោះផ្សាយត្រូវធៀបនឹងទ្រព្យសកម្មសរុប។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និង កែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងាររបស់គ្រប់អង្គភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងនៅថ្នាក់កណ្តាល និងនៅថ្នាក់មូលដ្ឋាន ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២
## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា២.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំនិងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ចនិងលើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារនិងសមធម៌សង្គម។

បេសកកម្មនេះ ត្រូវធ្វើឡើងតាមរយៈការរៀបចំនិងការអនុវត្តឱ្យបានត្រឹមត្រូវនូវគោលនយោបាយ ក្របខណ្ឌច្បាប់និងបទបញ្ញាទាំងឡាយ ដែលទាក់ទងនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ និងកិច្ចការវិនិយោគ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

ក្នុងគោលដៅលើកកម្ពស់អភិបាលកិច្ចល្អ ក្រុមប្រឹក្សានីតិកម្មត្រូវបង្កើតឡើងក្រោមការដឹកនាំផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានបេសកកម្មធានានីត្យានុកូលភាព និងសង្គតិភាពនៃការតាក់តែងលិខិតបទដ្ឋានគតិយុត្ត, រៀបចំនិងដាក់ឱ្យអនុវត្តឧបករណ៍ការងារគតិយុត្ត, លើកកម្ពស់ការយល់ដឹងនិងប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងផ្តល់ដំណោះស្រាយយុត្តិធម៌ ឬសមធម៌ដល់វិវាទ ឬបណ្តឹងនានាពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សានីតិកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានមុខងារនិងភារកិច្ច ដូចតទៅ÷

- រៀបចំ អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រងនិងសម្របសម្រួលកិច្ចការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពង្រឹងអភិបាលកិច្ចល្អ ទៅលើអ្វីដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
- វិភាគតាមដាន និងព្យាករស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង និងដាក់ចេញនូវវិធានការដើម្បីតម្រង់ទិសនិងកែលម្អការគ្រប់គ្រងសេដ្ឋកិច្ច
- សហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំនិងចូលរួមក្នុងការរៀបចំអនុវត្តគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល លើកិច្ចការសហប្រតិបត្តិការអន្តរជាតិ ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកិច្ចការសមាហរណកម្មកម្ពុជា ទៅក្នុងសេដ្ឋកិច្ចពិភពលោក ពិសេសកិច្ចការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាក្នុងក្របខណ្ឌអាស៊ាន

- ទទួលដឹកនាំ រៀបចំ ជំរុញអនុវត្ត និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- វិភាគ គ្រប់គ្រង និងតាមដានការវិវត្តនៃវិស័យហិរញ្ញវត្ថុ ព្រមទាំងចូលរួមរៀបចំនិងអនុវត្តក្របខណ្ឌគ្រប់គ្រងហានិភ័យនៃវិស័យហិរញ្ញវត្ថុ ដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ
- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ និងក្របខណ្ឌនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- កសាងប្រព័ន្ធហិរញ្ញវត្ថុឱ្យឯកភាពទូទាំងប្រទេស ហើយធានាអនុវត្តប្រព័ន្ធនេះ ឱ្យបានត្រឹមត្រូវតាមច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត
- ធ្វើការបែងចែក និងបែងចែកឡើងវិញនូវផលទុនជាតិ តាមរយៈការប្រមូលចំណូល និងថវិកានីយកម្មនៃចំណាយសាធារណៈ
- រៀបចំនិងកសាងសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ សម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាលក្ខណៈប្រចាំឆ្នាំនីមួយៗ ឬជាលក្ខណៈអចិន្ត្រៃយ៍
- រៀបចំនិងគ្រប់គ្រងថវិការដ្ឋ
- ចូលរួមរៀបចំគោលនយោបាយ និងគ្រប់គ្រងកិច្ចការវិនិយោគ
- ពិនិត្យនិងចុះទិដ្ឋាការលើចំណាយរបស់ក្រសួង និងស្ថាប័នរដ្ឋនានា
- រៀបចំនិងអនុវត្តគោលនយោបាយចំណូលថវិកាជាតិ
- ប្រមូលចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធ បង់ចូលបេឡាថវិការដ្ឋ ធ្វើតារាងតុល្យភាព និងវិភាគគណនីនៃប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ
- បំពេញមុខងារជាបេឡាករ និងគណនេយ្យករសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងរៀបចំគោលការណ៍និងបទបញ្ញាគណនេយ្យករសាធារណៈ
- គ្រប់គ្រងនិងត្រួតពិនិត្យកិច្ចការលទ្ធកម្មសាធារណៈនៃបណ្ដាក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល អង្គភាពរដ្ឋដទៃទៀត និង កិច្ចលទ្ធកម្មតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- អនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋ តាមក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែលនៅរដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលសាធារណៈដទៃទៀត និងនីតិបុគ្គលឯកជនដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ
- ចូលរួមកសាងនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទានពីក្នុងនិងក្រៅប្រទេស និងទទួលបន្ទុកគ្រប់គ្រងបំណុលសាធារណៈ
- ដឹកនាំ រៀបចំ និងអនុវត្តការងារដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម និងការងារអស្សាមិករណ៍ដោយសារគម្រោងអភិវឌ្ឍន៍នានា

- បំពេញមុខងារសវនកម្មផ្ទៃក្នុង និងជំរុញការអនុវត្តមុខងារសវនកម្មផ្ទៃក្នុងតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល
- បណ្ដុះបណ្ដាលនិងធ្វើវិក្រឹតការជាប្រចាំ នូវមុខជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដល់មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

**មាត្រា៤.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានរចនាសម្ព័ន្ធ ដូចខាងក្រោម÷

**ក-ថ្នាក់កណ្ដាល**

១-ខុទ្ទកាល័យរដ្ឋមន្ត្រី

២-អគ្គលេខាធិការដ្ឋាន

៣-អគ្គនាយកដ្ឋានគោលនយោបាយ

៤-អគ្គនាយកដ្ឋានថវិកា

៥-អគ្គនាយកដ្ឋានពន្ធដារ

៦-អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

៧-អគ្គនាយកដ្ឋានរតនាគារជាតិ

៨-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

៩-អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ

១០-អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

១១-អគ្គាធិការដ្ឋាន

១២-អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល

១៣-អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍

១៤-អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន

១៥-អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

១៦-វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ខ-ថ្នាក់មូលដ្ឋាន**

១-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត

២-សាខាពន្ធដារខេត្ត ខណ្ឌនានា នៃរាជធានី និងការិយាល័យពន្ធដារស្រុក ក្រុង

៣-សាខាគយនិងរដ្ឋាករខេត្ត ការិយាល័យគយនិងរដ្ឋាករត្រួតពិនិត្យបែបបទគយ និងបណ្ដាការិយាល័យគយនិងរដ្ឋាករដទៃទៀត

៤-រតនាគាររាជធានី ខេត្ត។

**មាត្រា៥.-**

អគ្គលេខាធិការដ្ឋាន ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អគ្គនាយកដ្ឋាន ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងមួយចំនួន ជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

វិទ្យាស្ថាន ដឹកនាំដោយនាយកមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយនាយករងមួយចំនួន ឋានៈស្មើអគ្គនាយករង ជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គភាពថ្នាក់ស្មើនាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួន ឋានៈស្មើអនុប្រធាននាយកដ្ឋាន ជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គភាពថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា៦.-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋាន ក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន និងអង្គភាពថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៧.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់ដោយអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន។

## ជំពូកទី៤
## អគ្គលេខាធិការដ្ឋាន

**មាត្រា៨.-**

អគ្គលេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មដូចតទៅ÷

- ផ្តល់សេវាគាំទ្រសម្រាប់ប្រក្រតីភាពនៃដំណើរការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួលសកម្មភាពការងាររវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទក្រសួង ពិសេសមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត

- ធ្វើជាលេខាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើផ្នែករដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក បច្ចេកវិទ្យាព័ត៌មាន បណ្ណសារ និងផែនការថវិកា។

**មាត្រា៩.-**

អគ្គលេខាធិការដ្ឋាន មានភារកិច្ចដូចតទៅ÷

- សម្របសម្រួលសកម្មភាពគ្រប់ថ្នាក់ គ្រប់ផ្នែករបស់ក្រសួង នៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ក្រោមឱវាទក្រសួង
- ប្រមូលផ្តុំ សម្របសម្រួល បូកសរុប និងលើកគម្រោងថវិកាប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រថវិកា និងអនុវត្តប្រតិបត្តិការចំណាយនិងកិច្ចបញ្ជិកាគណនេយ្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំ គ្រប់គ្រង និងអនុវត្តផែនការលទ្ធកម្មរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់ក្រសួង និងបែងចែកសម្ភារៈបរិក្ខារជូនគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំ និងបើកប្រាក់បៀវត្ស និងប្រាក់សង្គមកិច្ច ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំគម្រោង និងកម្មវិធីសាងសង់ ជួសជុល ថែទាំសំណង់ អគារ និងសម្ភារៈបរិក្ខារគ្រប់ប្រភេទរបស់ក្រសួង
- បំពេញតួនាទីជាអង្គភាពប្រមូលផ្តុំ លើការងារគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សរបស់ក្រសួង
- គ្រប់គ្រងបុគ្គលិក មន្ត្រីរាជការរបស់ក្រសួង ដោយទំនាក់ទំនងជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួង ស្ថាប័ន
- រៀបចំតួនាទីនិងតំណែងឯកទេសរបស់ស្ថាប័ន និងធនធានមនុស្ស
- រៀបចំផែនការនិងវាយតម្លៃតម្រូវការបណ្តុះបណ្តាលបុគ្គលិក មន្ត្រីរាជការរបស់ក្រសួង
- សិក្សានិងវាយតម្លៃតម្រូវការសម្រាប់កសាងឡើងវិញនូវសមត្ថភាពធនធានមនុស្ស និងបង្កើនគុណភាពវិជ្ជាជីវៈផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះមន្ត្រីក្រោមឱវាទក្រសួង
- រៀបចំផែនការជ្រើសរើសក្របខណ្ឌមន្ត្រីរាជការ ផែនការប្តូរប្រភេទក្របខណ្ឌមន្ត្រីរាជការ និងផែនការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកជាប់កិច្ចសន្យា
- រៀបចំការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ, ការដំឡើងថ្នាក់-ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយស និងមេដាយការងារ, ប្រាក់បំណាច់មុខងារ, ផ្ទេរភារកិច្ច ប្រគល់ភារកិច្ច, ពិនិត្យនីត្យានុកូលភាពលើការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ច, ការដាក់មន្ត្រីរាជការឱ្យនៅក្រៅក្របខណ្ឌដើម, ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស និងកិច្ចការពាក់ព័ន្ធបុគ្គលិកជារួមផ្សេងៗ
- គ្រប់គ្រងនិងអនុវត្តគម្រោង "ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដែលបានប្រសិទ្ធនាមថា ប្រព័ន្ធអេហ្វអឹមអាយអេស "FMIS")" នៅគ្រប់ដំណាក់កាលដើម្បីធានាសម្រេចឱ្យបាននូវគោលដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាលកម្ពុជា
- សហការ សម្របសម្រួល និងផ្តល់យោបល់ផ្នែកបច្ចេកទេសជូនថ្នាក់ដឹកនាំក្រសួង អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឌីជីថល

- រៀបចំ បង្កើត និង ពង្រឹងយុទ្ធសាស្ត្រ និងគោលនយោបាយបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដើម្បីទ្រទ្រង់ដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឌីជីថល
- ផ្តល់សេវាបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍នានា រួមមាន ការតភ្ជាប់បណ្តាញកុំព្យូទ័រ បណ្តាញអ៊ិនធឺណិត អ៊ីមែល និងការចែករំលែកឯកសារតាមបណ្តាញកុំព្យូទ័រ សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ស្រាវជ្រាវ បង្កើត និងអភិវឌ្ឍកម្មវិធីកុំព្យូទ័រថ្មីៗ និងលើកកម្ពស់នវានុវត្តន៍ និងការបង្កើតថ្មីផ្នែកបច្ចេកវិទ្យាព័ត៌មាន ដើម្បីបម្រើ និងសម្រួលដល់កិច្ចដំណើរការ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់គ្រង រៀបចំយុទ្ធសាស្ត្រ និងផ្សព្វផ្សាយ សម្រាប់ការផ្លាស់ប្តូរ ដែលពាក់ព័ន្ធនឹងការអនុវត្ត ឬ ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ទាំងក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្របខណ្ឌគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ទទួលបន្ទុកជាមជ្ឈមណ្ឌលព័ត៌មាន លើការអនុវត្តបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ជូនអង្គភាពទាំងអស់ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចូលរួមការងារកែសម្រួលនីតិវិធីអនុវត្តការងារ លើការគ្រប់គ្រង និងអនុវត្តប្រតិបត្តិការហិរញ្ញវត្ថុ និងថវិកា ជាមួយគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់គ្រង ថែរក្សាបណ្ណសារ ដែលជាឯកសាររបស់ក្រសួង និងជម្រះចោលនូវឯកសារ ដែលអស់សុពលភាព ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ជាអង្គភាពប្រមូលផ្តុំ និងតម្កល់ឯកសារ ទាំងឯកសាររឹង និងឯកសារទន់ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំប្រព័ន្ធពង្រឹងការគ្រប់គ្រង ពិនិត្យ តាមដាន និងថែរក្សារាល់ឯកសាររបស់ក្រសួង
- វាយតម្លៃប្រភេទឯកសារ ដោយបែងចែកឯកសារត្រូវតម្កល់ទុក និងឯកសារត្រូវជម្រះចោល
- រៀបចំ គ្រប់គ្រង និងធ្វើបច្ចុប្បន្នកម្មបញ្ជីឯកសារទាំងអស់របស់ក្រសួង
- សម្របសម្រួល និងទំនាក់ទំនងការងារជាមួយបណ្ណសារដ្ឋានជាតិ និងអង្គភាពពាក់ព័ន្ធ ក្នុងការប្រមូលយកឯកសារដែលមានលក្ខណៈប្រវត្តិសាស្ត្រទៅតម្កល់ទុក ឬ ការស្នើសុំគោលការណ៍ជម្រះឯកសារអស់តម្លៃចោល
- គ្រប់គ្រងការងារផែនការថវិកា ការតាមដានការអនុវត្ត និងការវាយតម្លៃសមិទ្ធកម្មក្នុងក្របខណ្ឌថវិកាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួលរៀបចំក្របខណ្ឌនៃការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវារដ្ឋបាល ទៅតាមនីតិវិធីរដ្ឋបាលជាធរមាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១០.-**

អគ្គលេខាធិការដ្ឋាន មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានបណ្ណសារ
- នាយកដ្ឋានផែនការថវិកា។

អគ្គលេខាធិការដ្ឋាន ទទួលបន្ទុកសម្របសម្រួលមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដែលជាតំណាងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្នាក់មូលដ្ឋាន។

**មាត្រា១១.-**

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងាររដ្ឋបាលនិងហិរញ្ញវត្ថុ។

នាយកដ្ឋានបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារបុគ្គលិក។

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារបច្ចេកវិទ្យាព័ត៌មាន។

នាយកដ្ឋានបណ្ណសារ បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារបណ្ណសារ។

នាយកដ្ឋានផែនការថវិកា បំពេញមុខងារជាសេនាធិការឱ្យអគ្គលេខាធិការដ្ឋាន លើការងារផែនការថវិកានិងការតាមដាននិងវាយតម្លៃលមិទ្ធកម្ម។

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាតំណាងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារសម្របសម្រួលអង្គភាពថ្នាក់មូលដ្ឋានរបស់ក្រសួង ព្រមទាំងអនុវត្តភារកិច្ចគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## អគ្គនាយកដ្ឋានគោលនយោបាយ

**មាត្រា១២.-**

អគ្គនាយកដ្ឋានគោលនយោបាយ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្ម ដូចតទៅ៖

- រៀបចំនិងតាមដានការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមដាននិងវាយតម្លៃនិន្នាការសេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោក ក្នុងកម្រិតវិស័យធំៗ ស្ទួចនាករម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំខាន់ៗ
- រៀបចំ និងតាមដានស្ថិតិហិរញ្ញវត្ថុសាធារណៈ
- ចូលរួមចំណែកក្នុងការងារពាក់ព័ន្ធដល់ការរៀបចំគោលនយោបាយពាណិជ្ជកម្ម និងហិរញ្ញវត្ថុក្រៅប្រទេស និងកិច្ច-សហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុក្នុងតំបន់និងពិភពលោក
- រៀបចំ តាមដាន និងវាយតម្លៃគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងប្រភពកំណើនថ្មី និងវិស័យសេដ្ឋកិច្ចអនាគត
- រៀបចំ តាមដាន និងវាយតម្លៃគោលនយោបាយពាក់ព័ន្ធនឹងប្រសិទ្ធភាពចំណាយ។

**មាត្រា១៣.-**

អគ្គនាយកដ្ឋានគោលនយោបាយ មានភារកិច្ច ដូចតទៅ៖

- រៀបចំ និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- សិក្សា និងវាយតម្លៃការវិវត្តសេដ្ឋកិច្ចជាតិទាំងមូល វិស័យធំៗ ស្ទួចនាករម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំខាន់ៗ ដើម្បីដាក់ចេញជាគោលនយោបាយ យុទ្ធសាស្ត្រ និងផ្តល់យោបល់ ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- តាមដាន និងវិភាគការអនុវត្តនិងការប្រព្រឹត្តទៅនៃហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីចំណូល និងចំណាយសាធារណៈ ហើយផ្ដែកលើមូលដ្ឋាននេះ លើកយោបល់និងស្នើវិធានការជូនថ្នាក់ដឹកនាំក្រសួងអំពីការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានប្រសិទ្ធភាព តម្លាភាព តុល្យភាព និងគណនេយ្យភាព
- រៀបចំក្របខណ្ឌចំណាយរយៈពេលមធ្យម និងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំ
- រៀបចំ និងវិភាគតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ និងស្ថិតិហិរញ្ញវត្ថុរាជរដ្ឋាភិបាល
- ផ្សព្វផ្សាយសកម្មភាពសេដ្ឋកិច្ច និងទិន្នន័យនានាដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រជាតិនានាជាមួយស្ថាប័នជាតិផ្សេងៗទៀត
- ចូលរួមរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងច្បាប់ទូទាត់ថវិកា
- ចូលរួមរៀបចំគោលនយោបាយពាណិជ្ជកម្ម និងហិរញ្ញវត្ថុក្រៅប្រទេស និងយុទ្ធសាស្ត្រសម្រាប់ចូលរួមការចរចា លើការបង្កើតតំបន់ពាណិជ្ជកម្មសេរី និងយន្តការសម្រាប់ការអនុវត្ត ប្រកបដោយប្រសិទ្ធភាព នៃកិច្ចព្រមព្រៀងទាំងនោះ
- សម្របសម្រួល និងតាមដានការងារពាក់ព័ន្ធកិច្ចសហប្រតិបត្តិការ ក្នុងវិស័យហិរញ្ញវត្ថុក្នុងតំបន់ និងពិភពលោក
- ធ្វើជាលេខាធិការដ្ឋានដើម្បីសម្របសម្រួលកម្រិតអគ្គនាយកដ្ឋាន ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះការអនុវត្តកាតព្វកិច្ចនានាពាក់ព័ន្ធជាមួយនឹងតំបន់ពាណិជ្ជកម្មសេរី ការសម្រួលពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ
- ពិនិត្យនិងផ្ដល់យោបល់អំពីការគ្រប់គ្រងមូលនិធិនានារបស់អាស៊ាន
- រៀបចំ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងការអភិវឌ្ឍទេពកោសល្យនិងសហគ្រិនភាព ប្រភពកំណើនថ្មី សេដ្ឋកិច្ចឌីជីថល សេដ្ឋកិច្ចច្នៃប្រឌិតនិងនវានុវត្តន៍ និងវិស័យសេដ្ឋកិច្ចអនាគត
- លើកកម្ពស់ការអនុវត្តការគិតគូរជាយុទ្ធសាស្ត្រសម្រាប់អនាគត ក្នុងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល
- រៀបចំ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយលើកទឹកចិត្តសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីជំរុញការអភិវឌ្ឍលើវិស័យសំខាន់ៗ សំដៅគាំទ្រការជំរុញកំណើនសេដ្ឋកិច្ច
- រៀបចំ តាមដាន និងវាយតម្លៃគោលនយោបាយពាក់ព័ន្ធនឹងគោលការណ៍ថ្លៃ សម្រាប់គាំទ្រដល់ការរៀបចំចំណាយសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
- ពិនិត្យ និងវាយតម្លៃផលចំណេញសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់គម្រោងវិនិយោគសាធារណៈ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃចំណាយសាធារណៈ
- សម្របសម្រួលការរៀបចំ និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអន្តរជាតិនានា ដែលមានលក្ខណៈម៉ាក្រូ និងអន្តរវិស័យ
- ផ្ដួចផ្ដើម សិក្សាស្រាវជ្រាវ និងសម្របសម្រួលលើការងាររៀបចំគោលនយោបាយអន្តរាគមន៍របស់រាជរដ្ឋាភិបាលសម្រាប់ធនាគារសហគ្រាសធុនតូចនិងមធ្យមកម្ពុជា, សាជីវកម្មធានាឥណទាន, និងគម្រោងបង្កើតសាជីវកម្មធានារ៉ាប់រងលើប្រាក់បញ្ញើ ព្រមទាំងការសម្របសម្រួលការងារលើកសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (IPO) របស់សហគ្រាសាធារណៈ

- ធ្វើជាលេខាធិការដ្ឋានដើម្បីសម្របសម្រួលរវាងអគ្គនាយកដ្ឋាន ឬអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនិយ័តករពាក់ព័ន្ធ លើការងារចូលរួមជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដើម្បីប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៤.-**

អគ្គនាយកដ្ឋានគោលនយោបាយ មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

- នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ
- នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច
- នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន
- នាយកដ្ឋានវិស័យសេដ្ឋកិច្ចថ្មី
- នាយកដ្ឋានប្រសិទ្ធភាពចំណាយ។

**មាត្រា១៥.-**

នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយ លើការងារគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងសារពើពន្ធ។

នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយ លើការងារស្ថិតិនិងវិភាគសេដ្ឋកិច្ច។

នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយ លើការងារសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាន។

នាយកដ្ឋានវិស័យសេដ្ឋកិច្ចថ្មី បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយ លើការងារវិស័យសេដ្ឋកិច្ចថ្មី។

នាយកដ្ឋានប្រសិទ្ធភាពចំណាយ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគោលនយោបាយលើការងារប្រសិទ្ធភាពចំណាយ។

## ជំពូកទី៦

## អគ្គនាយកដ្ឋានថវិកា

**មាត្រា១៦.-**

អគ្គនាយកដ្ឋានថវិកា បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងថវិកាជាតិក្នុងគោលដៅធានាឱ្យមានការបែងចែកនិងប្រើប្រាស់ធនធានថវិការដ្ឋ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងចីរភាព។

**មាត្រា១៧.-**

អគ្គនាយកដ្ឋានថវិកា មានភារកិច្ចដូចតទៅ÷

- កសាងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងបទបញ្ញាហិរញ្ញវត្ថុសាធារណៈ



ហ

- រៀបចំការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ហិរញ្ញវត្ថុ បទបញ្ញាហិរញ្ញវត្ថុសាធារណៈ និងច្បាប់ដែលមានការពាក់ព័ន្ធផ្សេងទៀត
- ចូលរួមក្នុងការងារកសាងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា
- រៀបចំកម្មវិធីចំណាយសាធារណៈទៀងទាត់ ដោយផ្អែកលើកម្មវិធីចំណូលសាធារណៈ ដែលត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់ដំណើរការជាប្រចាំ និងសម្រាប់គម្រោងវិនិយោគសាធារណៈរបស់ក្រសួង ស្ថាប័ន ដោយផ្អែកលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងកម្មវិធីវិនិយោគប្រចាំឆ្នាំដែលបានទទួលការអនុម័តរួច
- ត្រួតពិនិត្យហិរញ្ញវត្ថុលើការអនុវត្តចំណាយថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- ចូលរួមសហការក្នុងការត្រួតពិនិត្យ និងតាមដានលើការអនុវត្តនីតិវិធីចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ
- រៀបចំអាទិភាពវិនិយោគប្រចាំឆ្នាំ សម្រាប់គោលបំណងថវិកានីយកម្មលើគម្រោងវិនិយោគសាធារណៈដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- សិក្សា និងវាយតម្លៃបច្ចេកទេសគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានថវិកាក្នុងប្រទេសថ្នាក់ជាតិ
- សម្របសម្រួល និងណែនាំបច្ចេកទេសដល់ក្រសួង ស្ថាប័ននានា ក្នុងក្របខណ្ឌនៃការតាមដាន និងរៀបចំរបាយការណ៍សមិទ្ធកម្ម
- សម្របសម្រួល និងផ្តល់យោបល់ដល់ក្រសួង ស្ថាប័ន អង្គភាពថវិកាក្នុងការរៀបចំ និងកែលម្អការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ លទ្ធផលចុងក្រោយ និងការរៀបចំកម្មវិធីក្នុងក្របខណ្ឌនៃការអនុវត្តថវិកាកម្មវិធី និងការឈានទៅអនុវត្តថវិកាសមិទ្ធកម្ម
- ធ្វើការតាមដាន និងវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៨.-**

អគ្គនាយកដ្ឋានថវិកា មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានថវិកានីយកម្ម
- នាយកដ្ឋានហិរញ្ញកិច្ច
- នាយកដ្ឋានវិនិយោគ
- នាយកដ្ឋានតាមដាន និងវាយតម្លៃ។

**មាត្រា១៩.-**

នាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារគ្រប់គ្រងកិច្ចការទូទៅ។

នាយកដ្ឋានថវិកានីយកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារថវិកានីយកម្ម។

នាយកដ្ឋានហិរញ្ញកិច្ច បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារហិរញ្ញកិច្ច។

នាយកដ្ឋានវិនិយោគ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារវិនិយោគ។

នាយកដ្ឋានតាមដាន និងវាយតម្លៃ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារតាមដាន និងវាយតម្លៃសមិទ្ធកម្ម នៃការអនុវត្តថវិកា។

**ជំពូកទី៧**

**អគ្គនាយកដ្ឋានពន្ធដារ**

**មាត្រា២០.-**

អគ្គនាយកដ្ឋានពន្ធដារ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មធ្វើឱ្យសម្រេចនូវការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារ ដូចតទៅ÷

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារ
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ និងអនុវត្តទោសទណ្ឌ តាមការកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ ចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារ
- ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- ផ្តល់សេវានិងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរពនិងអនុវត្តត្រឹមត្រូវ
- អនុវត្តកម្មវិធីចាប់បង្ខំ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីសារពើពន្ធ
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារ ដើម្បីបង្កើនជំនឿទុកចិត្តចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធីនិងកិច្ចដំណើរការរបស់ខ្លួន ធ្វើឱ្យមានភាពសាមញ្ញចំពោះតម្រូវការផ្សេងៗ និងបន្ថយចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន។

**មាត្រា២១.-**

អគ្គនាយកដ្ឋានពន្ធដារ មានភារកិច្ចដូចតទៅ÷

- រៀបចំគោលនយោបាយសារពើពន្ធនិងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដោយផ្អែកលើការអង្កេតនិងផ្ទុំព័ត៌មាន

- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ពន្ធប្រថាប់ត្រា ការប្រាក់ និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ ចំពោះអ្នកជាប់ពន្ធនិងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២២.-**

អគ្គនាយកដ្ឋានពន្ធដារ គឺជារដ្ឋបាលសារពើពន្ធ ដែលមានប្រព័ន្ធចាត់តាំងឯកភាព ទទួលខុសត្រូវគ្រប់គ្រងទូទាំងប្រទេស និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៣.-**

អគ្គនាយកដ្ឋានពន្ធដារ មានរចនាសម្ព័ន្ធនៅថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន ដូចខាងក្រោម÷

**ក-ថ្នាក់កណ្តាល**

- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក
- នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
- នាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- នាយកដ្ឋានសវនកម្មសហគ្រាស
- សាលាជាតិពន្ធដារ ថ្នាក់ស្មើនាយកដ្ឋាន
- ទីចាត់ការពន្ធដាររាជធានីភ្នំពេញ ថ្នាក់ស្មើនាយកដ្ឋាន។

**ខ-ថ្នាក់មូលដ្ឋាន**

នៅខណ្ឌនានា នៃរាជធានីភ្នំពេញ និងខេត្តនីមួយៗ មានសាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត ដែលដឹកនាំដោយប្រធានម្នាក់ មានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល និងអនុប្រធានសាខាពន្ធដារមួយចំនួន ឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាល ជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នៅស្រុក ក្រុង មានការិយាល័យពន្ធដារស្រុក ក្រុង មានថ្នាក់ស្មើការិយាល័យនៃសាខាពន្ធដារខេត្ត ខណ្ឌ និងដឹកនាំដោយប្រធានម្នាក់ អមដោយអនុប្រធានមួយចំនួន ជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២៤.-**

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងាររដ្ឋបាលនិងកិច្ចការទូទៅ។

នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារហិរញ្ញវត្ថុ និងបុគ្គលិក។

នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារនីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ។

នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារគ្រប់គ្រងពន្ធចលនទ្រព្យ និងអចលនទ្រព្យ។

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារបច្ចេកវិទ្យាព័ត៌មាន។

នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារស៊ើបអង្កេតបទល្មើសពន្ធដារ។

នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារគ្រប់គ្រងអ្នកជាប់ពន្ធធំ។

នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារគ្រប់គ្រងសាខាពន្ធដារខេត្ត ខណ្ឌ។

នាយកដ្ឋានសវនកម្មសហគ្រាស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារសវនកម្មសហគ្រាស។

សាលាជាតិពន្ធដារ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារបណ្តុះបណ្តាលមុខជំនាញទាក់ទងនឹងពន្ធដារ។

ទីចាត់ការពន្ធដាររាជធានីភ្នំពេញ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារសម្របសម្រួលការងារសាខាពន្ធដារខណ្ឌទាំងអស់នៅរាជធានីភ្នំពេញ។

សាខាពន្ធដារខេត្ត ខណ្ឌ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងារគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងអ្នកជាប់ពន្ធដទៃទៀតតាមការចាំបាច់។

## ជំពូកទី៨

## អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

**មាត្រា២៥.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មដូចតទៅ៖

- ទទួលខុសត្រូវក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗ លើទំនិញនាំចេញ នាំចូល ឬឆ្លងកាត់ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីគយ ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលពាក់ព័ន្ធនឹងការនាំចេញ ការនាំចូល ការឆ្លងកាត់ ការធ្វើចរាចរ និងការធ្វើសន្និធិទំនិញ

- រៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តចាំបាច់ក្នុងការគ្រប់គ្រងត្រួតពិនិត្យលើការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូន ទំនិញនាំចេញ នាំចូល ឬឆ្លងកាត់
- ចូលរួមបង្ការ និងទប់ស្កាត់ភេរវកម្មនិងអំពើវិទ្ធង្សនាសេដ្ឋកិច្ច ដើម្បីសន្តិសុខនិងសុវត្ថិភាពសង្គម
- ជំរុញការបង្ការ និងការបង្ក្រាបអំពើល្មើស និងអំពើរត់ពន្ធ
- ចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ជំរុញការអនុវត្តតាមស្តង់ដាអន្តរជាតិ និងឧត្តមានុវត្តន៍ដែលពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យគយ និងការសម្រួលពាណិជ្ជកម្ម ជាពិសេសការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ និងការធ្វើស្វ័យប្រវត្តិកម្មគយ។

**មាត្រា២៦.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានភារកិច្ចដូចតទៅះ

- លើកសំណើគោលនយោបាយ ដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរពាណិជ្ជកម្មអន្តរជាតិ និងរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការងារគ្រប់គ្រងប្រមូលពន្ធនិងអាករនាំចេញ នាំចូល លើទំនិញគ្រប់ប្រភេទ ជាពិសេសពិនិត្យពិចារណាក្នុងការកសាងនិងអនុវត្តតារាងពន្ធគយ និងនីតិវិធីទាំងឡាយ ដែលទាក់ទងនឹងការងារគយនិងរដ្ឋាករឱ្យបានសមស្របទៅតាមដំណាក់កាលនីមួយៗ នៃការវិវត្តសេដ្ឋកិច្ចជាតិនិងអន្តរជាតិ
- កសាងស្ថិតិទំនិញពាណិជ្ជកម្ម
- ជាស្ថាប័ននាំមុខតែមួយគត់ដែលទទួលខុសត្រូវលើការគ្រប់គ្រងត្រួតពិនិត្យការធ្វើចរាចរ ការធ្វើសន្និធិទំនិញនាំចេញ ឬនាំចូល នៅមាត់ច្រកព្រំដែន និងមានភារកិច្ចសម្របសម្រួលឱ្យមានការត្រួតពិនិត្យរួមគ្នាតែមួយលើក ក្នុងករណីដែលតម្រូវឱ្យមានការត្រួតពិនិត្យដោយស្ថាប័នផ្សេងទៀត ស្របតាមការកំណត់រកឃើញហានិភ័យ
- គ្រប់គ្រង ត្រួតពិនិត្យ និងអនុវត្តការប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗ លើទំនិញនាំចេញ ឬនាំចូលគ្រប់ប្រភេទ
- លើកវិធានការរាំងខ្ទប់និងចាប់ឃាត់ទំនិញរត់ពន្ធគយគ្រប់ប្រភេទ
- ត្រួតពិនិត្យ តាមដាន និងគ្រប់គ្រងការនាំចេញ-នាំចូលទំនិញគ្រប់ប្រភេទ ទោះមាន ឬគ្មានលក្ខណៈពាណិជ្ជកម្មក្តី ដោយរាប់បញ្ចូលទាំងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកដំណើរ ឬផ្លាស់ប្តូរលំនៅឋាន រូបិយប័ណ្ណ លោហធាតុ-ត្បូងថ្មមានតម្លៃ បេតិកភណ្ឌវប្បធម៌ និងភណ្ឌិការប្រៃសណីយ៍ ព្រមទាំងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ
- លើកគម្រោងជ្រើសរើសនិងបណ្តុះបណ្តាលជំនាញបច្ចេកទេស មន្ត្រី បុគ្គលិក និងភ្នាក់ងារគយនិងរដ្ឋាករ
- អនុវត្តនយោបាយសមាហរណកម្មសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ ពាក់ព័ន្ធនឹងការងារគយនិងរដ្ឋាករ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៧.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានប្រព័ន្ធចាត់តាំងគ្រប់គ្រងឯកភាពទូទាំងប្រទេស មានសិទ្ធិដឹកនាំនិងត្រួតពិនិត្យលើរាល់អង្គភាពគយនិងរដ្ឋាករពីថ្នាក់កណ្តាលរហូតដល់ថ្នាក់មូលដ្ឋាន តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៨.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានរចនាសម្ព័ន្ធនៅថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន ដូចខាងក្រោម÷

**ក-ថ្នាក់កណ្តាល**

- លេខាធិការដ្ឋាន ថ្នាក់ស្មើនាយកដ្ឋាន
- នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក
- នាយកដ្ឋានផែនការនិងបច្ចេកទេស
- នាយកដ្ឋានកិច្ចការច្បាប់និងទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានសវនកម្មគយ
- នាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស
- នាយកដ្ឋានរដ្ឋាករ
- នាយកដ្ឋានរបបគយ
- នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ
- នាយកដ្ឋានគ្រប់គ្រងការនាំចេញ
- នាយកដ្ឋានគយនិងរដ្ឋាកររាជធានីភ្នំពេញ
- សាលាជាតិគយ ថ្នាក់ស្មើនាយកដ្ឋាន។

**ខ-ថ្នាក់មូលដ្ឋាន**

អង្គភាពមូលដ្ឋាននៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមមាន÷

- បណ្តាសាខាគយនិងរដ្ឋាករ ដែលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល និងអនុប្រធានមួយចំនួន ឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាល ជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- បណ្តាការិយាល័យគយនិងរដ្ឋាករក្រោមឱវាទសាខាគយនិងរដ្ឋាករ ដែលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាល និងអនុប្រធានមួយចំនួន ឋានៈស្មើអនុប្រធានការិយាល័យនៅថ្នាក់កណ្តាល ជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២៩.-**

លេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារលេខាធិការដ្ឋានរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារហិរញ្ញវត្ថុនិងបុគ្គលិក។

នាយកដ្ឋានផែនការនិងបច្ចេកទេស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារផែនការនិងបច្ចេកទេស។

នាយកដ្ឋានកិច្ចការច្បាប់និងទំនាក់ទំនងសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារច្បាប់ និងទំនាក់ទំនងសាធារណៈ។

នាយកដ្ឋានសវនកម្មគយ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារសវនកម្មគយ។

នាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារបង្ការនិងបង្ក្រាបបទល្មើស។

នាយកដ្ឋានរដ្ឋាករ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងាររដ្ឋាករ។

នាយកដ្ឋានរបបគយ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងាររបបគយ។

នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារគ្រប់គ្រងតំបន់រួចពន្ធ។

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារបច្ចេកវិទ្យាព័ត៌មាន។

នាយកដ្ឋានសហប្រតិបត្តិការគយអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារសហប្រតិបត្តិការគយអន្តរជាតិ។

នាយកដ្ឋានគ្រប់គ្រងការនាំចេញ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារគ្រប់គ្រងការនាំចេញ។

នាយកដ្ឋានគយនិងរដ្ឋាកររាជធានីភ្នំពេញ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារអនុលោមភាពនិងបង្ក្រាបបទល្មើសគយក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។

សាលាជាតិគយ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លើការងារបណ្តុះបណ្តាលមុខជំនាញទាក់ទងនឹងគយនិងរដ្ឋាករ។

## ជំពូកទី៩
## អគ្គនាយកដ្ឋានរតនាគារជាតិ

**មាត្រា៣០.-**

អគ្គនាយកដ្ឋានរតនាគារជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងឋានៈជាបេឡាករនិងជាគណនេយ្យករសាធារណៈរបស់រាជរដ្ឋាភិបាល លើបេសកកម្មគ្រប់គ្រងការអនុវត្តថវិកានិងគណនេយ្យ និងគ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងចីរភាព។

**មាត្រា៣១.-**

អគ្គនាយកដ្ឋានរតនាគារជាតិ មានភារកិច្ច ដូចតទៅ÷

- គ្រប់គ្រងសាច់ប្រាក់របស់រដ្ឋ
- គ្រប់គ្រងគណនីរបស់ក្រសួង ស្ថាប័នថ្នាក់កណ្តាល គណនីរបស់មន្ទីរជំនាញរាជធានី ខេត្ត គណនីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គណនីនៃថវិកាឧបសម្ព័ន្ធ គណនីប្រាក់បញ្ញើនានា និងគណនីពិសេសរតនាគារ
- ចូលរួមគ្រប់គ្រងមូលបត្ររដ្ឋ

- ធ្វើតុល្យភាពសាច់ប្រាក់ និងគ្រប់គ្រងចំណូល-ចំណាយថវិកាជាតិ
- កាន់កាប់ និងតាមដានការអនុវត្តគណនេយ្យទូទៅ និងមជ្ឈការគណនី
- រៀបចំនិងតាមដានការអនុវត្តគោលការណ៍ និងបទបញ្ញាគណនេយ្យសាធារណៈ ឱ្យស្របតាមស្តង់ដាគណនេយ្យសាធារណៈជាតិនិងអន្តរជាតិ សម្រាប់រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋ
- ផ្តល់សេវាដល់គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ លើការទូទាត់ ការចំណាយផ្សេងៗ ការបើកបៀវត្ស និងការទទួលចំណូល ស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- សហការជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ចូលរួមរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដទៃទៀត
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣២.-**

អគ្គនាយកដ្ឋានរតនាគារជាតិមានរចនាសម្ព័ន្ធនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ដូចខាងក្រោម÷

**ក-ថ្នាក់កណ្តាល**

- នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
- នាយកដ្ឋានចំណូលថវិកា
- នាយកដ្ឋានចំណាយថវិកា
- នាយកដ្ឋានគណនេយ្យ
- នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាន និងសរុបស្ថិតិ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- អធិការកិច្ចរតនាគារ ថ្នាក់ស្មើនាយកដ្ឋាន
- នាយកដ្ឋានគ្រប់គ្រងសាច់ប្រាក់
- នាយកដ្ឋានគោលការណ៍គណនេយ្យ និងវិភាគការអនុវត្តថវិកា។

**ខ-ថ្នាក់មូលដ្ឋាន**

នៅរាជធានី ខេត្ត មានរតនាគាររាជធានីភ្នំពេញ និងរតនាគារខេត្ត។

រតនាគាររាជធានី ខេត្ត ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល អមដោយអនុប្រធានមួយចំនួន ជាជំនួយការ ឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាល អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣៣.-**

នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារហិរញ្ញវត្ថុនិងបុគ្គលិក។

នាយកដ្ឋានចំណូលថវិកា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារចំណូលថវិកា។

នាយកដ្ឋានចំណាយថវិកា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារចំណាយថវិកា។

នាយកដ្ឋានគណនេយ្យ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគណនេយ្យ។

នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ។

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារបច្ចេកវិទ្យាព័ត៌មាន។

អធិការកិច្ចរតនាគារ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារអធិការកិច្ចរតនាគារ។

នាយកដ្ឋានគ្រប់គ្រងសាច់ប្រាក់ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគ្រប់គ្រងសាច់ប្រាក់។

នាយកដ្ឋានគោលការណ៍គណនេយ្យ និងវិភាគការអនុវត្តថវិកា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានរតនាគារជាតិ លើការងារគោលការណ៍គណនេយ្យសាធារណៈ និងវិភាគការអនុវត្តថវិកា។

## ជំពូកទី១០

## អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

**មាត្រា៣៤.-**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣៥.-**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មានភារកិច្ចដូចតទៅ÷

- រៀបចំ បង្កើត អនុវត្ត និងតាមដានការអនុវត្តគោលនយោបាយលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ត្រួតពិនិត្យនិងតាមដានលើរាល់កិច្ចលទ្ធកម្មសាធារណៈដែលអនុវត្តដោយស្ថាប័នអនុវត្តលទ្ធកម្ម
- ពិនិត្យនិងលើកយោបល់លើតារាងផែនការលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- ពិនិត្យនិងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃ
- ពិនិត្យនិងលើកយោបល់លើសំណើសុំគោលការណ៍អនុវត្តវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្ម
- ពិនិត្យនិងលើកយោបល់លើសំណើសុំប្រគល់កិច្ចសន្យាលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- គ្រប់គ្រងនិងតាមដានការអនុវត្តកិច្ចសន្យាលទ្ធកម្មរបស់ស្ថាប័នអនុវត្តលទ្ធកម្ម
- គ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ
- ចូលរួមដោះស្រាយវិវាទលទ្ធកម្ម

- បណ្តុះបណ្តាលអំពីការអនុវត្តវិធាននិងបទប្បញ្ញត្តិនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ដល់មន្ត្រីលទ្ធកម្មនៃស្ថាប័នអនុវត្តលទ្ធកម្ម មន្ត្រីពាក់ព័ន្ធដទៃទៀត អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ និងអ្នកទទួលការ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៦.-**

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

- នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ
- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ
- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា
- នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ
- នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ។

**មាត្រា៣៧.-**

នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងាររៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ ការងាររដ្ឋបាល បុគ្គលិក បញ្ជិកាអ្នកដេញថ្លៃ ផែនការលទ្ធកម្ម និងការងារគ្រប់គ្រងកិច្ចសន្យាលទ្ធកម្ម។

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងារគ្រប់គ្រងលទ្ធកម្មទំនិញ ដែលអនុវត្តដោយក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត។

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសំណង់និងសេវា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងារគ្រប់គ្រងលទ្ធកម្មសំណង់ សេវាកម្ម និងសេវាទីប្រឹក្សាដែលអនុវត្តដោយក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត។

នាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងារគ្រប់គ្រងលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ លើការងារត្រួតពិនិត្យនិងដោះស្រាយវិវាទពាក់ព័ន្ធលទ្ធកម្មសាធារណៈ។

## ជំពូកទី១១

## អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ

**មាត្រា៣៨.-**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

**មាត្រា៣៩.-**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មានភារកិច្ច ដូចតទៅ÷

- រៀបចំសេចក្ដីព្រាងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានា ទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រងនិងជំរុញការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ នៅទូទាំងប្រទេស
- ស្រាវជ្រាវនិងគ្រប់គ្រងទ្រព្យឥតម្ចាស់ និងមរតកឥតបណ្ដឹង
- គ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រងភាគហ៊ុនរបស់រដ្ឋនិងដើមទុនរបស់រដ្ឋ
- គ្រប់គ្រងសហគ្រាសសាធារណៈ អង្គភាពសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត
- ប្រមូលផ្ដុំព័ត៌មានពាក់ព័ន្ធការងារឯកជនភាវូបនីយកម្ម ការជម្រុះបញ្ជីសហគ្រាសសាធារណៈ និងអង្គភាពរដ្ឋដទៃទៀត
- គ្រប់គ្រងនិងរៀបចំបញ្ជីសម្បទានដីសេដ្ឋកិច្ច សម្បទានព្រៃឈើ សម្បទានរ៉ែ និងសម្បទានដទៃទៀត ដែលបានផ្ដល់ឱ្យវិស័យឯកជន
- រៀបចំនីតិវិធីវាយតម្លៃការដាក់ជួល លក់ ដូរ និងផ្ទេរសិទ្ធិទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងការរៀបចំផែនការប្រមូលចំណូល និងបំណុលមិនមែនសារពើពន្ធដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន លើការងារប្រមូលចំណូលមិនមែនសារពើពន្ធនិងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- រក្សាការពារទិន្នន័យ នៃការគ្រប់គ្រងការប្រមូលចំណូលនិងបំណុលមិនមែនសារពើពន្ធ និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ស្រាវជ្រាវរកប្រភពចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤០.-**

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

- នាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានចំណូលសាធារណៈ
- នាយកដ្ឋានសហគ្រាសសាធារណៈ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា៤១.-**

នាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

នាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិរដ្ឋ។

នាយកដ្ឋានចំណូលសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងចំណូលសាធារណៈ។

នាយកដ្ឋានសហគ្រាសសាធារណៈ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារគ្រប់គ្រងសហគ្រាសសាធារណៈ។

នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ លើការងារបច្ចេកវិទ្យាព័ត៌មាន។

## ជំពូកទី១២
## អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា៤២.-**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មអនុវត្តការងារគ្រប់គ្រងហិរញ្ញវត្ថុ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា៤៣.-**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ មានភារកិច្ច ដូចតទៅ÷

- រៀបចំការអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- កសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ពិគ្រោះយោបល់ជាមួយអគ្គនាយកដ្ឋាន នាយកដ្ឋានជំនាញ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំការផ្ទេរមុខងារនិងធនធាន ព្រមទាំងរៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់បម្រើដល់ការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- ចូលរួមជាមួយអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំសារាចររបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំថវិកា និងការអនុវត្តថវិកា
- សម្របសម្រួលជាមួយអង្គភាពនានា នៃក្រសួង ស្ថាប័ន ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- រួមចំណែកក្នុងការកៀរគរចំណូលពីប្រភពនានា ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន សម្រាប់រួមចំណែកដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- កសាងសមត្ថភាពនិងផ្តល់ការបណ្តុះបណ្តាល និងគាំទ្រដល់ការរៀបចំ ការអនុម័ត និងការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ត្រួតពិនិត្យ តាមដានការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមដានរំហូរធនធានទៅក្នុងមូលនិធិនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានមកពីដៃគូអភិវឌ្ឍ និងសប្បុរសជន
- សម្របសម្រួលជាមួយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ក្នុងការរៀបចំ អនុម័ត និងអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤៤.-**

អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

- នាយកដ្ឋានគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេស
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី១
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី២
- នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី៣។

**មាត្រា៤៥.-**

នាយកដ្ឋានគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេស បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងរដ្ឋបាលនិងបច្ចេកទេស។

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី១ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលរាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកោះកុង និងក្រុង ស្រុក ខណ្ឌ ព្រមទាំងឃុំ សង្កាត់ នៃរាជធានី ខេត្ត ទាំងនេះ។

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី២ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម និងក្រុង ស្រុក ព្រមទាំងឃុំ សង្កាត់ នៃខេត្ត ទាំងនេះ។

នាយកដ្ឋានគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិទី៣ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ លើការងារគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តក្រចេះ ខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង ខេត្តស្វាយរៀង និងក្រុង ស្រុក ព្រមទាំងឃុំ សង្កាត់ នៃខេត្ត ទាំងនេះ។

## ជំពូកទី១៣
## អគ្គាធិការដ្ឋាន

**មាត្រា៤៦.-**

អគ្គាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មធ្វើអធិការកិច្ចហិរញ្ញវត្ថុលើអនុលោមភាពនិងសមិទ្ធកម្ម នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋ ដោយប្រើអភិក្រម ផ្អែកលើហានិភ័យ ករណីសង្ស័យ បណ្ដឹងតវ៉ា និងបណ្ដឹងបរិហារ។

**មាត្រា៤៧.-**

អគ្គាធិការដ្ឋាន មានភារកិច្ចដូចតទៅ÷

- ធ្វើអធិការកិច្ចហិរញ្ញវត្ថុលើកិច្ចដំណើរការរដ្ឋបាលថ្នាក់ជាតិ គ្រប់ក្រសួង ស្ថាប័ន អង្គភាព និងកិច្ចដំណើរការរដ្ឋបាលថ្នាក់ក្រោមជាតិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុងវិន័យ និងការអនុវត្តនីតិវិធីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុចំណូល-ចំណាយថវិកាជាតិ និងការទទួលខុសត្រូវការគ្រប់គ្រងការប្រើប្រាស់សាច់ប្រាក់របស់រដ្ឋ
- ធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋតាមក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែលនៅរដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងនីតិបុគ្គលសាធារណៈដទៃទៀត

- ធ្វើអធិការកិច្ចហិរញ្ញវត្ថុលើរាល់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់នីតិបុគ្គលឯកជន ដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈទោះតាមរូបភាពណាក៏ដោយ ជាអាទិ៍ ក្រុមហ៊ុនឯកជន សម្បទានិក ស្ថាប័នមីក្រូហិរញ្ញវត្ថុ សហជីព សមាគម អង្គការមិនមែនរដ្ឋាភិបាល
- ធ្វើអធិការកិច្ចហិរញ្ញវត្ថុក្នុងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ ថវិកាសម្រាប់បើកផ្តល់មុននិងក្រោយចំណាយ លើគ្រប់ក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ អង្គភាពសាធារណៈ អង្គការ សមាគម សហគមន៍ និងក្រុមហ៊ុនខាងលើ តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ធ្វើអធិការកិច្ចត្រួតពិនិត្យឯកសារពាក់ព័ន្ធ លើករណីដែលមានការកិបកេង ការក្លែងបន្លំឯកសារនានាពាក់ព័ន្ធហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ប្រភពធនធានរដ្ឋ និងធនធានហិរញ្ញវត្ថុសាធារណៈ ដើម្បីទប់ស្កាត់ការប្រព្រឹត្តអំពើពុករលួយ
- ធ្វើអធិការកិច្ចត្រួតពិនិត្យការគ្រប់គ្រងមូលនិធិសាធារណៈ ប្រភពទុន ប្រភពធនធានជាតិ និងប្រភពមូលនិធិ ដែលមានការចូលរួមពីសង្គម សាធារណជននានា ស្ថិតក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទប្បញ្ញត្តិពាក់ព័ន្ធ
- ធ្វើអធិការកិច្ចហិរញ្ញវត្ថុលើគម្រោងវិនិយោគសាធារណៈ គម្រោងឥណទាន ថវិកាបដិភាគ របស់រាជរដ្ឋាភិបាល និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ
- ធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងទ្រព្យសម្បត្តិរដ្ឋតាមបច្ចេកវិទ្យាព័ត៌មាន
- ទទួលពាក្យបណ្តឹង ពិនិត្យបណ្តឹង និងធ្វើអធិការកិច្ចហិរញ្ញវត្ថុតាមពាក្យបណ្តឹង ដែលទាក់ទងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ
- ចុះផ្សព្វផ្សាយនិងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដល់មន្ត្រីដែលកំពុងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យទទួលខុសត្រូវតាមវិធានការវិន័យរដ្ឋបាលនិងតុលាការ
- ជំរុញ ពង្រឹងកៀរគរចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ ចំណូលផ្សេងៗ ដោយតម្រូវឱ្យមានការបំពេញកាតព្វកិច្ចបង់ចំណូលចូលថវិកាជាតិ ឱ្យបានគ្រប់ចំនួននិងទាន់ពេលវេលា
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- លើកសំណើដំណោះស្រាយ និង/ឬចាត់វិធានការចំពោះអង្គភាពនិង/ឬបុគ្គលពាក់ព័ន្ធ ដែលបានប្រព្រឹត្តកំហុសឆ្គង ដើម្បីចូលរួមធានាការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤៨.-**

អគ្គាធិការដ្ឋាន មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

- នាយកដ្ឋានរដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្តឹង
- នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី១
- នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី២
- នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី៣។

**មាត្រា៤៩.-**

នាយកដ្ឋានរដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្ដឹង បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋាន លើការងាររដ្ឋបាល ផែនការ និងសិក្សាស្រាវជ្រាវបណ្ដឹង។

នាយកដ្ឋានអធិការកិច្ចហិរញ្ញវត្ថុទី១ ទី២ និងទី៣ បំពេញមុខងារជាសេនាធិការឱ្យអគ្គាធិការដ្ឋាន លើការងារអធិការកិច្ចហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងនីតិបុគ្គលឯកជនដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១៤
## អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល

**មាត្រា៥០.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលសាធារណៈ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាព។

**មាត្រា៥១.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល មានភារកិច្ច ដូចតទៅ÷

- រៀបចំ និងចរចាលើរាល់កិច្ចព្រមព្រៀងរបស់រដ្ឋ ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានឥតសំណង ការទទួលហិរញ្ញប្បទានឥតសំណង ការខ្ចីប្រាក់ពីគេ ការឱ្យប្រាក់គេខ្ចី ព្រមទាំងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងៗទៀត
- គ្រប់គ្រង និងសម្របសម្រួលការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ
- គ្រប់គ្រងបំណុលសាធារណៈ
- ចូលរួមអភិវឌ្ឍមូលបត្ររដ្ឋ
- សហការជាមួយក្រសួង ស្ថាប័ន ក្នុងការត្រួតពិនិត្យ និងតាមដានលើការអនុវត្តនីតិវិធីចំណាយថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ និងថវិកាបដិភាគ
- ចូលរួមកសាងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងច្បាប់ទូទាត់ថវិកា
- សហប្រតិបត្តិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុអន្តរជាតិជាមួយអង្គភាពពាក់ព័ន្ធ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងដៃគូពាក់ព័ន្ធនានា
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥២.-**

អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានសហប្រតិបត្តិការទ្វេភាគី

- នាយកដ្ឋានសហប្រតិបត្តិការពហុភាគី
- នាយកដ្ឋានគ្រប់គ្រងបំណុល
- នាយកដ្ឋានតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង។

**មាត្រា៥៣.-**

នាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារគ្រប់គ្រងទូទៅ។

នាយកដ្ឋានសហប្រតិបត្តិការទ្វេភាគី បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារសហប្រតិបត្តិការទ្វេភាគី។

នាយកដ្ឋានសហប្រតិបត្តិការពហុភាគី បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារសហប្រតិបត្តិការពហុភាគី។

នាយកដ្ឋានគ្រប់គ្រងបំណុល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារគ្រប់គ្រងបំណុលសាធារណៈ។

នាយកដ្ឋានតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល លើការងារតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ។

## ជំពូកទី១៥

## អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍

**មាត្រា៥៤.-**

អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើបេសកកម្មដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍នានា។

**មាត្រា៥៥.-**

អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ មានភារកិច្ច ដូចតទៅ÷

- អនុវត្តតាមការណែនាំ ការបញ្ជា និងសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍នានា
- ដឹកនាំការអនុវត្តការងារដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍នានា ទាំងចំពោះគម្រោងវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល និងគម្រោងវិនិយោគឯកជនដែលអនុវត្តក្នុងក្របខណ្ឌភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងតម្រូវការនៃការអភិវឌ្ឍជាតិ និងដែលតម្រូវឱ្យមានការធ្វើលទ្ធកម្មដី សិទ្ធិ និងទ្រព្យសម្បត្តិផ្សេងៗ សម្រាប់បម្រើឱ្យការអនុវត្តគម្រោង
- ចូលរួមសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការងារសិក្សាសមិទ្ធិលទ្ធភាពគម្រោងនិងការងាររៀបចំគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ដើម្បីវាយតម្លៃ និងកាត់បន្ថយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច-សង្គម សំដៅរួមចំណែកកាត់បន្ថយបន្ទុកចំណាយរបស់រាជរដ្ឋាភិបាល លើការងារដោះស្រាយផលប៉ះពាល់ និងកាត់បន្ថយបញ្ហាប្រឈមនានាឱ្យនៅកម្រិតអប្បបរមា ក្នុងដំណាក់កាលអនុវត្តគម្រោង

- រៀបចំផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍
- ពិនិត្យនិងផ្តល់យោបល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រៀបចំសំណើសុំការអនុម័តលើផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍
- ពិនិត្យនិងផ្តល់យោបល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើឯកសារគតិយុត្តផ្សេងៗរបស់គម្រោងដែលមានការពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់ និងការធ្វើលទ្ធកម្មដីសម្រាប់បម្រើឱ្យការអនុវត្តគម្រោង
- ចូលរួមចរចាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានរបស់រដ្ឋជាមួយដៃគូអភិវឌ្ឍនានា ចំពោះផ្នែកដែលពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម និងការធ្វើលទ្ធកម្មដីសម្រាប់គម្រោង
- រៀបចំក្រុមការងារតាមតម្រូវការចាំបាច់ជាក់ស្តែង ផ្អែកលើសំណើបច្ចេកទេសរបស់ក្រសួង ស្ថាប័នអនុវត្តគម្រោង ដើម្បីចុះធ្វើការអង្កេតវាស់វែងលម្អិត និងវាយតម្លៃអំពីផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ដែលតម្រូវឱ្យមានការធ្វើលទ្ធកម្មដី សំណង់ផ្ទះសម្បែង សិទ្ធិ និងទ្រព្យសម្បត្តិផ្សេងៗសម្រាប់បម្រើឱ្យការអនុវត្តគម្រោង
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ និងកិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដើម្បីផ្សព្វផ្សាយឱ្យបានទូលាយ និងច្បាស់លាស់អំពីក្របខណ្ឌច្បាប់ នីតិវិធី គោលការណ៍ និងគោលនយោបាយដោះស្រាយផលប៉ះពាល់ដោយសារគម្រោង ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋរងផលប៉ះពាល់នៅតាមទីតាំងគម្រោងនីមួយៗ
- រៀបចំឱ្យមានយន្តការវាយតម្លៃដី និងទ្រព្យសម្បត្តិផ្សេងៗដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ដើម្បីជាមូលដ្ឋានសម្រាប់ទូទាត់សំណងឱ្យបានសមរម្យនិងយុត្តិធម៌ ជូនប្រជាពលរដ្ឋរងផលប៉ះពាល់
- ធ្វើការតាមដានត្រួតពិនិត្យផ្ទៃក្នុង លើការអនុវត្តផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍ ដើម្បីធានានូវអនុលោមភាពនិងប្រសិទ្ធភាព នៃការអនុវត្តការងារ
- រៀបចំឱ្យមានការតាមដានត្រួតពិនិត្យពីខាងក្រៅដោយភ្នាក់ងារឯករាជ្យចំពោះអនុលោមភាព នៃការអនុវត្តផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម
- ចូលរួមជាមួយតំណាងក្រសួង ស្ថាប័នអនុវត្តគម្រោង និងអាជ្ញាធរដែនដីនៅពេលប្រគល់ទទួលគម្រោងដែលបានសាងសង់ ស្តារ ឬជួសជុលរួច ដើម្បីពិនិត្យផ្ទៀងផ្ទាត់លើការប្រើប្រាស់ជាក់ស្តែងនូវដី ឬទ្រព្យសម្បត្តិដែលត្រូវបានធ្វើលទ្ធកម្មសម្រាប់បម្រើឱ្យគម្រោង ហើយដែលបានប្រើប្រាស់ថវិកាជាតិ ឬថវិកាដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការនានា
- សហការជាមួយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋាន ឬអង្គភាពជំនាញនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នអនុវត្តគម្រោង ក្នុងការរៀបចំឱ្យមានការចុះបញ្ជីដីធ្លីក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ចំពោះដីដែលបានធ្វើលទ្ធកម្មសម្រាប់គម្រោងនិងដែលបានប្រគល់ជូនក្រសួង ស្ថាប័នអនុវត្តគម្រោង ដើម្បីកាន់កាប់ និងគ្រប់គ្រងបន្ត
- តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងករណីដែលមានបណ្តឹងតវ៉ាទៅតុលាការទាក់ទងនឹងការងារដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ឬបញ្ហាទូទាត់សងសំណង ឬលក្ខណៈសម្បត្តិក្នុងការទទួលបាននូវប្រាក់សំណង និង/ឬប្រាក់ឧបត្ថម្ភផ្សេងៗ

- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងគ្រប់គ្រងទិន្នន័យផលប៉ះពាល់ នៃគម្រោងនីមួយៗ ដែលទទួលបានពីក្រសួង ស្ថាប័នអនុវត្តគម្រោង
- រៀបចំសំណើថវិកាពេញលេញសម្រាប់ការសិក្សា ការរៀបចំ និងការអនុវត្តផែនការសកម្មភាពដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ដោយផ្អែកលើលទ្ធផលនៃការអង្កេតវាស់វែងលម្អិតអំពីផលប៉ះពាល់ និងលទ្ធផលនៃការសិក្សាវាយតម្លៃថ្លៃដី និងទ្រព្យសម្បត្តិផ្សេងៗដែលទទួលរងផលប៉ះពាល់
- សហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តការងារដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍
- សិក្សា ស្រាវជ្រាវ រៀបចំ និងកសាងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងគោលនយោបាយដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍ ដោយមានការចូលរួមពីអង្គភាពពាក់ព័ន្ធ
- រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព របស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិតអំពីក្របខណ្ឌច្បាប់ នីតិវិធី គោលការណ៍ និងគោលនយោបាយពាក់ព័ន្ធនឹងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នានា
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥៦.-**

អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុងនិងគ្រប់គ្រងទិន្នន័យ
- នាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី១
- នាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី២
- នាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី៣។

**មាត្រា៥៧.-**

នាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ លើការងារគ្រប់គ្រងបុគ្គលិក រដ្ឋបាល ហិរញ្ញវត្ថុ ច្បាប់និងផែនការ និងបច្ចេកវិទ្យាព័ត៌មាន។

នាយកដ្ឋានត្រួតពិនិត្យផ្ទៃក្នុងនិងគ្រប់គ្រងទិន្នន័យ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ លើការងារត្រួតពិនិត្យផ្ទៃក្នុង ការងារគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការងារទទួលពិនិត្យពាក្យបណ្តឹងតវ៉ានិងទំនាក់ទំនងសាធារណៈ។

នាយកដ្ឋានដោះស្រាយផលប៉ះពាល់ទី១ ទី២ និងទី៣ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ លើការងារដោះស្រាយផលប៉ះពាល់ដល់ដីធ្លី សំណង់ផ្ទះសម្បែង សិទ្ធិ និងទ្រព្យសម្បត្តិផ្សេងៗដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នានា តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១៦
## អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន

**មាត្រា៥៨.-**

អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្ម ក្នុងការទទួលពិនិត្យ និងវាយតម្លៃរាល់សំណើគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន (ហៅកាត់ ភ.រ.ជ.) ក្នុងគ្រប់ដំណាក់កាលនៃវដ្តគម្រោង។

**មាត្រា៥៩.-**

អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន មានភារកិច្ច ដូចតទៅ÷

- ផ្តល់យោបល់លើការអភិវឌ្ឍគោលនយោបាយ ភ.រ.ជ. និងដឹកនាំការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តយន្តការ ភ.រ.ជ.
- ពិនិត្យ និងផ្តល់យោបល់លើការអនុម័តសំណើគម្រោង ភ.រ.ជ.ដើម្បីធ្វើអាទិភាវូបនីយកម្មសំណើគម្រោង ភ.រ.ជ.ទៅក្នុងបញ្ជីគម្រោងអាទិភាព ភ.រ.ជ.
- រៀបចំគោលការណ៍ណែនាំស្តីពីការវិភាគហិរញ្ញវត្ថុ
- ពិនិត្យ និងផ្តល់យោបល់លើសមិទ្ធិលទ្ធភាពផ្នែកហិរញ្ញវត្ថុរបស់សំណើគម្រោង ភ.រ.ជ.
- ពិនិត្យ និងផ្តល់យោបល់លើការបែងចែកហានិភ័យនៃគម្រោង ភ.រ.ជ. រវាងភាគីរដ្ឋ និងដៃគូឯកជន
- រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហានិភ័យ និងការគាំទ្ររបស់រដ្ឋ
- ពិនិត្យ និងផ្តល់យោបល់លើកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងការគាំទ្ររបស់រដ្ឋ សម្រាប់គម្រោង ភ.រ.ជ.
- ពិនិត្យ និងផ្តល់យោបល់លើកិច្ចសន្យា ភ.រ.ជ. និងកិច្ចព្រមព្រៀងពាក់ព័ន្ធផ្សេងទៀត
- សហការជាមួយស្ថាប័នសាមី និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីពិនិត្យ និងតាមដានការអនុវត្តកាតព្វកិច្ចរបស់គូភាគី ដោយអនុលោមតាម ខ និងលក្ខខណ្ឌ នៃកិច្ចសន្យា ភ.រ.ជ. និងបទដ្ឋានគតិយុត្តជាធរមាន
- ពិនិត្យ និងផ្តល់យោបល់លើថវិកាប្រចាំឆ្នាំរបស់ស្ថាប័នសាមីពាក់ព័ន្ធនឹងកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងការគាំទ្ររបស់រដ្ឋ ក្រោមក្របខណ្ឌគម្រោង ភ.រ.ជ.
- រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការធ្វើបច្ចុប្បន្នកម្មនៃកាតព្វកិច្ចហិរញ្ញវត្ថុសាធារណៈ និងការគាំទ្រពីរដ្ឋ ក្រោមក្របខណ្ឌកិច្ចសន្យា ភ.រ.ជ. ដែលត្រូវបំពេញដោយភាគីរដ្ឋ
- រៀបចំថវិកា គ្រប់គ្រង និងធ្វើប្រតិបត្តិការមូលនិធិអភិវឌ្ឍន៍គម្រោង និងមូលនិធិបំពេញផលហិរញ្ញវត្ថុ
- ផ្តល់ការគាំទ្រដល់ការរៀបចំអភិវឌ្ឍន៍គម្រោង ភ.រ.ជ. និងការបណ្តុះបណ្តាលសមត្ថភាពពាក់ព័ន្ធនឹងការអភិវឌ្ឍគម្រោង ការត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោង ភ.រ.ជ. ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យសម្រាប់កម្មវិធី/គម្រោង ភ.រ.ជ. នៅកម្ពុជា
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦០.-**

អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន មាននាយកដ្ឋានក្រោមឱវាទចំនួន ៣ ដូចខាងក្រោម÷

- នាយកដ្ឋានកិច្ចការទូទៅ

- នាយកដ្ឋានអភិវឌ្ឍន៍គម្រោង
- នាយកដ្ឋានប្រគល់ និងត្រួតពិនិត្យគម្រោង។

**មាត្រា៦១.-**

នាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន លើការងារគ្រប់គ្រងរដ្ឋបាលទូទៅ។

នាយកដ្ឋានអភិវឌ្ឍន៍គម្រោង បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន លើការរៀបចំអភិវឌ្ឍន៍សំណើគម្រោង ភ.រ.ជ. ចាប់ពីដំណាក់កាលធ្វើអត្តសញ្ញាណកម្មគម្រោង រហូតដល់ដំណាក់កាលអនុម័តគម្រោង ព្រមទាំងផ្តល់ការគាំទ្រចាំបាច់នានាដល់ស្ថាប័នសាមី សម្រាប់ការពិនិត្យ និងវាយតម្លៃសំណើគម្រោង ការសិក្សាសមិទ្ធិលទ្ធភាពគម្រោង និងផ្តល់យោបល់លើការអនុម័តគម្រោង។

នាយកដ្ឋានប្រគល់ និងត្រួតពិនិត្យគម្រោង បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន លើការអនុវត្តលទ្ធកម្ម និងតាមដានការអនុវត្តគម្រោង ភ.រ.ជ. ចាប់ពីដំណាក់កាលកិច្ចលទ្ធកម្មគម្រោង និងចុះកិច្ចសន្យា រហូតដល់ដំណាក់កាលការអនុវត្តគម្រោង និងគ្រប់គ្រងកិច្ចសន្យា ភ.រ.ជ. ព្រមទាំងផ្តល់ការគាំទ្រចាំបាច់នានាដល់ស្ថាប័នសាមីនៅក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិការ និងថែទាំគម្រោង រហូតដល់ការប្រគល់នូវទ្រព្យសម្បត្តិ និងសេវាកម្មពាក់ព័ន្ធរបស់គម្រោងជូនមករដ្ឋវិញ។

## ជំពូកទី១៧
## អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា៦២.-**

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធភាពប្រតិបត្តិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាំមុខក្នុងការអភិវឌ្ឍមុខងារសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល។

**មាត្រា៦៣.-**

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង មានភារកិច្ច ដូចតទៅ÷

- រៀបចំនិងអនុវត្តគោលការណ៍ណែនាំ ផែនការ នីតិវិធី និងស្តង់ដាពាក់ព័ន្ធសវនកម្មផ្ទៃក្នុង
- តាមដាននិងជំរុញដំណើរការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល
- រៀបចំនិងអនុវត្តកម្មវិធីបណ្តុះបណ្តាល ពាក់ព័ន្ធការអភិវឌ្ឍមុខងារសវនកម្មផ្ទៃក្នុង ឱ្យស្ថិតក្នុងកម្រិតឧត្តមានុវត្តន៍
- ទំនើបកម្មការងារគាំទ្រ និងការងារសវនកម្មរបស់អគ្គនាយកដ្ឋាន
- រៀបចំផែនការអភិវឌ្ឍន៍អគ្គនាយកដ្ឋាន ផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុង និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ
- វាយតម្លៃអំពីប្រសិទ្ធភាព នៃការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំដៅពង្រឹងអភិបាលកិច្ចល្អ

- ចូលរួមផ្ដល់ប្រឹក្សាសវនកម្មដោយឯករាជ្យ និងសត្យានុម័ត ក្នុងយន្តការការងារនានា លើការរៀបចំឯកសារយុទ្ធសាស្ត្រ គោលនយោបាយ ផែនការ កម្មវិធី និងឯកសារពាក់ព័ន្ធ រួមទាំងការដំឡើងប្រព័ន្ធនានា
- ធ្វើរបាយការណ៍ត្រង់ទៅប្រធានស្ថាប័ន ដោយធ្វើច្បាប់ចតចម្លងទៅអាជ្ញាធរសវនកម្មជាតិ និងសម្របសម្រួលការងារជាមួយសមត្ថកិច្ចត្រួតពិនិត្យនានា
- ជាលេខាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការផ្ដល់មតិចំពោះការស្នើសុំមិនបង្កើតមុខងារសវនកម្មផ្ទៃក្នុងរបស់អង្គភាពលើកសំណើ
- រៀបចំនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនិងបច្ចេកទេសពាក់ព័ន្ធសវនកម្មផ្ទៃក្នុង ជូនក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល
- បណ្ដុះបណ្ដាលពង្រឹងសមត្ថភាពជំនាញសវនកម្មផ្ទៃក្នុងតាមស្តង់ដាឧត្តមានុវត្តន៍អន្តរជាតិ
- ជំរុញ និងពង្រឹងការអនុវត្តកាតព្វកិច្ចរបស់សវនកម្មផ្ទៃក្នុង ស្របតាមគោលការណ៍កំណត់
- តាមដាន និងជំរុញបង្កើនប្រសិទ្ធភាពសវនកម្មផ្ទៃក្នុងតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋាន
- រៀបចំគោលការណ៍ ស្តង់ដា និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងអនុវត្តសវនកម្មបច្ចេកវិទ្យា-ព័ត៌មាន
- រៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ជំនាញសវនកម្មបច្ចេកវិទ្យាព័ត៌មានរយៈពេលវែង មធ្យម និង ខ្លី
- ធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអង្គភាពទាំងឡាយក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅថ្នាក់កណ្ដាល និងថ្នាក់មូលដ្ឋាន និង តាមដានការអនុវត្តអនុសាសន៍
- ចូលរួមផ្ដល់ប្រឹក្សាពាក់ព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្នុងយន្តការការងារនានា លើការរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ ផែនការ កម្មវិធីពាក់ព័ន្ធការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន ដោយឯករាជ្យ និងសត្យានុម័ត
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៤.-**

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

- នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់កណ្ដាល
- នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់មូលដ្ឋាន
- នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានបច្ចេកទេសសវនកម្ម។

**មាត្រា៦៥.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់កណ្ដាល បំពេញមុខងារជាលេខាធិការឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង លើការងារសវនកម្មផ្ទៃក្នុង នៅតាមអង្គភាពនានាក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅអង្គភាពថ្នាក់កណ្ដាល។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងថ្នាក់មូលដ្ឋាន បំពេញមុខងារជាលេខាធិការឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង លើការងារសវនកម្មផ្ទៃក្នុង នៅតាមអង្គភាពនានាក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅអង្គភាពថ្នាក់មូលដ្ឋាន។

នាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន បំពេញមុខងារជាលេខាធិការឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មសវនកម្មបច្ចេកវិទ្យាព័ត៌មាន។

នាយកដ្ឋានបច្ចេកទេសសវនកម្ម បំពេញមុខងារជាលេខាធិការឱ្យអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង លើការងារសវនកម្មនីតិកម្ម ស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ។

## ជំពូកទី១៨
## វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**មាត្រា៦៦.-**

វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាលេខាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ លើមុខជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានបេសកកម្ម ដូចខាងក្រោម÷

- កសាង និងអភិវឌ្ឍសមត្ថភាពជូនមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័ន ព្រមទាំងអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការផ្តល់ការបណ្តុះបណ្តាល និងវិក្រឹតការលើមុខជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការ លើការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធបណ្តុះបណ្តាល និងទិន្នន័យឌីជីថល សម្រាប់គាំទ្រការកសាង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៧.-**

វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ច ដូចតទៅ÷

- អនុវត្តការបណ្តុះបណ្តាល និងវិក្រឹតការ លើមុខជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមបច្ចេកវិទ្យាព័ត៌មាន ជូនមន្ត្រីរាជការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន រួមនិងអង្គភាពជំនាញពាក់ព័ន្ធក្រោមឱវាទ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- អនុវត្តការសិក្សាស្រាវជ្រាវ និងប្រមូលធាតុចូលស្តីពីការអនុវត្តគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ពង្រឹង និងកែលម្អការអនុវត្តការងារបណ្តុះបណ្តាល សំដៅលើកកម្ពស់ការយល់ដឹងជូនមន្ត្រីរាជការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- អនុវត្តការរៀបចំ គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធទិន្នន័យបច្ចេកវិទ្យាព័ត៌មាន សម្រាប់គាំទ្រការកសាង និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការលើជំនាញពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុវត្តការសិក្សាវាយតម្លៃប្រសិទ្ធភាព និងកំណត់អំពីតម្រូវការនៃការស្រាវជ្រាវ ការហ្វឹកហ្វឺន ការបណ្តុះបណ្តាល និងវិក្រឹតការជូនមន្ត្រីរាជការលើជំនាញសម្រាប់ការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយទាក់ទង និងសហការជាមួយគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងស្ថាប័នដៃគូពាក់ព័ន្ធ

- ផ្តួចផ្តើម និងកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាព សម្រាប់ការបណ្តុះបណ្តាល និងវិក្រឹតការ លើជំនាញការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ គាំទ្រដល់ការអភិវឌ្ឍ និង ការធ្វើបច្ចុប្បន្នភាពជំនាញ សមត្ថភាព ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន
- ផ្តួចផ្តើម និងសម្របសម្រួលការអនុវត្តការងារស្រាវជ្រាវ បណ្តុះបណ្តាល និងវិក្រឹតការ ដោយបង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងស្ថាប័នស្រាវជ្រាវ និងគ្រឹះស្ថានអប់រំ បណ្តុះបណ្តាល ទាំងជាតិ និងអន្តរជាតិ ដើម្បីធ្វើទំនើបកម្មកម្មវិធីស្រាវជ្រាវ បណ្តុះបណ្តាល និងវិក្រឹតការ និង លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បោះពុម្ព និងផ្សព្វផ្សាយលទ្ធផល នៃការស្រាវជ្រាវ និងឯកសារសិក្សាសំខាន់ៗពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំ និងសម្របសម្រួលការផ្ទេរ និងចែករំលែកចំណេះដឹង ជំនាញ និងឧត្តមានុវត្តន៍ពីទីប្រឹក្សា និងអ្នកជំនាញការទាំងក្នុងស្រុក និងអន្តរជាតិ ជូនដល់មន្ត្រីរាជការ គ្រូបង្គោល គ្រូឧទ្ទេស និងសាស្ត្រាចារ្យ
- អភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធបណ្តុះបណ្តាលឌីជីថលគាំទ្រការងារកសាង និងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ
- រៀបចំ និងអនុវត្តប្រព័ន្ធបណ្តុះបណ្តាល និងវិក្រឹតការពីចម្ងាយ
- អភិវឌ្ឍ និងគ្រប់គ្រងការរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ប្រព័ន្ធគ្រប់គ្រងចំណេះដឹង និងបណ្ណាល័យសម្រាប់ការងារកសាង និងអភិវឌ្ឍសមត្ថភាព
- អភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពព័ត៌មាន និងទិន្នន័យឌីជីថល
- រៀបចំរបាយការណ៍ស្តីពីសកម្មភាពនៃការស្រាវជ្រាវ ការហ្វឹកហ្វឺន ការបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៨.-**

វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ ដូចខាងក្រោម÷

- នាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ
- នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍ
- នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធឌីជីថល ។

**មាត្រា៦៩.-**

នាយកដ្ឋានបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារគ្រប់គ្រងបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ។

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារបណ្តុះបណ្តាល និងវិក្រឹតការ។

នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍ បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ។

នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធឌីជីថល បំពេញមុខងារជាសេនាធិការឱ្យវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការងារគ្រប់គ្រងប្រព័ន្ធបណ្តុះបណ្តាលឌីជីថល និងទិន្នន័យឌីជីថល។

## ជំពូកទី១៩
## អន្តរភាពមូលដ្ឋាន

**មាត្រា៧០.-**

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត បំពេញមុខងារជាតំណាងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការសម្របសម្រួលនិងគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអភិបាលហិរញ្ញវត្ថុ នៅរាជធានី ខេត្ត ដោយធ្វើការសម្របសម្រួលរវាងរដ្ឋបាលថ្នាក់ជាតិផ្សេងទៀតនៅថ្នាក់មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយអង្គភាពថ្នាក់មូលដ្ឋាននិងអង្គភាពថ្នាក់កណ្ដាលទាំងឡាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី២០
## អន្តរប្បញ្ញត្តិ

**មាត្រា៧១.-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្កើត ឬការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន និងអង្គភាពថ្នាក់មូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលកំពុងអនុវត្ត ត្រូវបន្តអានុភាពអនុវត្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មកជំនួស។

## ជំពូកទី២១
## អវសានប្បញ្ញត្តិ

**មាត្រា៧២.-**

អនុក្រឹត្យនេះ ត្រូវជំនួសអនុក្រឹត្យ ដូចខាងក្រោម៖

- អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ស្ដីពីការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការដំឡើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, ដំឡើងនាយកដ្ឋានសហប្រតិបត្តិការនិងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១៤ រោច ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកាត់ឆ្វៀលដីទំហំ ៣ហិកតា ៣៧អា ស្ថិតនៅភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលកាន់កាប់ជាក់ស្តែង

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបទបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ឆ្វៀលដីទំហំ ៣ហិកតា ៣៧អា ស្ថិតនៅភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងចំណុចនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ចេញពីដែនគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ។

**មាត្រា ២.-**

ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីទំហំ ៣ហិកតា ៣៧អា ស្ថិតនៅភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ជូនឈ្មោះ ជា សុខឡេង ដែលកាន់កាប់ជាក់ស្តែង។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៤រោច ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ពស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មីនា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

## ប្លង់គំនូសបន្លាញទីតាំងដី និងចំណុចនិយាមការភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...៤៩ អនក្រ.បក...ចុះថ្ងៃទី...២.....ខែ.មីនា....ឆ្នាំ២០២២

## ស្តីពីការស្នើសុំកាត់ឆ្វៀលចេញពីគម្របព្រៃឈើឆ្នាំ២០០២ ទំហំ ៣ហិកតា ៣៧អា

## ស្ថិតនៅភូមិ៤ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ




| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 342541.242 | 1181480.788 | 10 | 342634.476 | 1181656.791 |
| 2 | 342510.421 | 1181564.964 | 11 | 342628.386 | 1181632.141 |
| 3 | 342476.389 | 1181660.386 | 12 | 342623.387 | 1181614.017 |
| 4 | 342478.119 | 1181665.886 | 13 | 342617.028 | 1181593.87 |
| 5 | 342579.494 | 1181796.957 | 14 | 342608.343 | 1181570.72 |
| 6 | 342622.155 | 1181760.668 | 15 | 342602.143 | 1181554.457 |
| 7 | 342659.546 | 1181765.864 | 16 | 342598.571 | 1181530.166 |
| 8 | 342649.258 | 1181721.456 | 17 | 342597.28 | 1181519.664 |
| 9 | 342643.9 | 1181697.777 | 18 | 342585.527 | 1181456.731 |

មាត្រដ្ឋាន១:៣ 000
Coordinate System:
Projection :UTM
Zone :48N
Horizantal Datum :WGS 84
UTM Grid : 100 m

## តារាងចំណុចនិយាមការគោលព្រំទីតាំងដីរបស់ឈ្មោះ ជា សុខឡេង

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 342541.242 | 1181480.788 | 7 | 342659.546 | 1181765.864 | 13 | 342617.028 | 1181593.87 |
| 2 | 342510.421 | 1181564.964 | 8 | 342649.258 | 1181721.456 | 14 | 342608.343 | 1181570.72 |
| 3 | 342476.389 | 1181660.386 | 9 | 342643.9 | 1181697.777 | 15 | 342602.143 | 1181554.457 |
| 4 | 342478.119 | 1181665.886 | 10 | 342634.476 | 1181656.791 | 16 | 342598.571 | 1181530.166 |
| 5 | 342579.494 | 1181796.957 | 11 | 342628.386 | 1181632.141 | 17 | 342597.28 | 1181519.664 |
| 6 | 342622.155 | 1181760.668 | 12 | 342623.387 | 1181614.017 | 18 | 342585.527 | 1181456.731 |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ១៣៤.អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ចុះថ្ងៃទី៣០ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១:** ប្រគល់ភារកិច្ចជូនលោក **សូ សុហ៊ុន** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ របស់ក្រសួងផែនការ ជំនួសលោក **វ៉ា សុផល** ដែលបានទទួលភារកិច្ចថ្មី ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃ ពុធ ៧ កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥*

*ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០២២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៣៥ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ២០២១ ដល់មន្ត្រីរាជការចំនួន ៥៣ រូប នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-លោក **ឆាន សំណាង** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ២-លោក **ហេង សុតា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៣-លោកស្រី **តាន់ ឧត្តរី** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៤-លោក **យោង ចាន់សុតា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៥-លោក **យស សុខេមរិន** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៦-លោក **ឈុន ទីរ៉ា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |

| | | |
|---|---|---|
| ៧-លោក **ឈួននី ស៊ីណាន** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៨-លោក **កែវ ប៊ុនឫទ្ធិ** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៩-លោក **យិន ឆយ** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១០-លោកស្រី **អ៊ុជ ច័ន្ទសត្យា** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១១-លោកស្រី **សាយ និមល** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១២- ឯកឧត្តម **សុខ សូភេន** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៣-លោក **លឹម សម្បត្តិ** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៤-លោកស្រី **ម៉ក់ សុធីតា** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៥-លោក **អ៊ុន តារា** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៦-ឯកឧត្តម **ជីនបូរាណា ច័ន្ទបូរី** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៧-លោក **គិត សុធារិទ្ធ** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៨-លោក **សម ជីវ័ន្ត** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៩-លោក **ចាន់ សុជា** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២០-លោកស្រី **ចន្ធូនា នីតា** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២១-លោក **ព្រីង សុខ** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២២-លោក **ម៉ៅ ដារ៉េត** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៣-លោក **លីន ច័ន្ទអក្ខដា** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៤-លោកស្រី **អ៊ិត សុនិសា** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៥-លោកស្រី **មាច សុតាវី** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៦-លោក **គួច ឆាវ៉ាត់** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៧-លោកស្រី **ហេង សុម៉ូលី** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៨- ឯកឧត្តម **ស៊ឹម វីរៈ** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ២៩-លោកស្រី **ឡាំ បញ្ញាពរ** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣០-លោក **សុខ រិទ្ធី** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣១-លោកស្រី **ជួប វណ្ណៈ** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣២-លោក **អ៊ីត អ៊ីសា** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣៣-លោក **គួយ គុណាភក្តី** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣៤-លោក **សាប់ សំខាន់** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣៥-លោក **ជា តារ័ត្ន** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣៦-លោក **ទី ហុងលីម** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣៧-លោកស្រី **សឿង សុលីដា** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣៨-លោកស្រី **សារឹម ពិសិដ្ឋ** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣៩-លោក **ឡួង ឆៃនី** | ពីវមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |

| | | |
|---|---|---|
| ៤០-លោក **អៀង សេងហេង** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤១-លោក **យ៉ាន សាក់ណារតហ្សេ** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤២-លោកស្រី **រ៉ៃ វិជ្ជាសុតា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤៣-លោក **ហុង សុវណ្ណារ៉ា** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤៤-លោក **ឡួន សុត័ក្រ** | ពីវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤៥-លោក **ហាន សេរីពុទ្ធា** | ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១<br>មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | |
| ៤៦-លោកស្រី **ខេន សៀកឡាយ** | ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១<br>មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | |
| ៤៧-លោក **សុខ សំអាត** | ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១<br>មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | |
| ៤៨-លោក **ពេជ្រ សុផានី** | ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១<br>មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | |
| ៤៩-លោក **រ៉ាត់ សិរីវឌ្ឍនា** | ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១<br>មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | |
| ៥០-លោក **អង សុត័ក្រាដារ៉ាវិទូ** | ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១<br>មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | |
| ៥១-លោក **ឃាង ម៉េងឈុន** | ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១<br>មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | |
| ៥២-លោកស្រី **អ៊ុំ វាសនា** | ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១<br>មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | |
| ៥៣-លោក **សុខ ម៉េងស្រ៊ុន** | ពីអនុមន្ត្រីការបរទេស ថ្នាក់លេខ ១<br>មកជាវរមន្ត្រីការបរទេស ថ្នាក់លេខ ៤ | |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧ កើត ខែ ផល្គុន ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៦.អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួល សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៥៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល "គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ" ទៅជា "គណកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ"

-បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

### សម្រេច

**មាត្រា ១** : តែងតាំងលោកស្រី **ឡុច សៀន** ជាជំនួយការ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧ កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

នៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មីនា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៣៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១.**.បំពាក់មេដាយ**ស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន១២រូប ដែលបានបរិច្ចាគបច្ច័យ និងធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តគិរីអម្ពរ(អន្លង់ពោង) ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំកន្លងមក ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

ក-មេដាយ**មាសស្ថាបនាជាតិ**

| | | |
|---|---|---|
| ១- ព្រះគ្រូញាណប្បគុណោ (ជោតធម្ម) | **អយ សុខធា** | ព្រះចៅអធិការវត្តគិរីអម្ពរ (អន្លង់ពោង) |
| ២- ភិក្ខុខន្តិសាពោ | **ហ៊ីន អំណាត់** | ព្រះសង្ឃគង់វត្តគិរីអម្ពរ (អន្លង់ពោង) |

| | | |
|---|---|---|
| ៣- ភិក្ខុជីវិតបណ្ឌិតោ | **ណោត វុទ្ធី** | ព្រះចៅអធិការវត្តមុនីវណ្ណារាម(អន្លង់វៀន)ខេត្តក្រចេះ |
| ៤- ភិក្ខុជីនវរោ | **ជីន រ៉ុង** | ព្រះចៅអធិការវត្តវនសិលារុក្ខារាម(ដីសម្បទាន)ខេត្តក្រចេះ |
| ៥- ភិក្ខុជោតវណ្ណោ | **រិន វិរៈ** | ព្រះចៅអធិការវត្តរតនារាមចង្រ្កង់ជ័យ(ចង្រ្កង់)ខេត្តក្រចេះ |
| ៦- ភិក្ខុមហាមុនីសិរីបញ្ញោ | **សែម វិរៈ** | ព្រះចៅអធិការវត្តប្រាសាទបញ្ចរតនារាម(កសាង)ខេត្តក្រចេះ |

ខ-មេដាយ**សំរឹទ្ធស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- លោកជំទាវ | **ស៊ុន សារ៉ែន** | សប្បុរសជន | ថវិកាចំនួន ១៥០០ ដុល្លារ |
| ២- ឧបាសក | **ស្រ៊ុន ស្រេង** | គណៈកម្មធិការវត្ត | ថវិកាចំនួន ១០០០ ដុល្លារ |
| ៣- ឧបាសិកា | **ហាង់ ស៊ីលាត** | សប្បុរសជន | ថវិកាចំនួន ១០០០ ដុល្លារ |
| ៤- អ្នកស្រី | **ធីម ស្រី** | សប្បុរសជន | ថវិកាចំនួន ២ ០០០ ដុល្លារ |
| ៥- ឧបាសក | **មៀន យី** | សប្បុរសជន | ថវិកាចំនួន ១ ០០០ ដុល្លារ |
| ៦- អ្នកស្រី | **នួន ធីតា** | សប្បុរសជន | ថវិកាចំនួន ១ ០០០ ដុល្លារ |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ថ្ងៃ ពុធ ៧ កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែ មីនា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៣៨ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពី**

**ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ២០២១ ដល់មន្ត្រីរាជការចំនួន ២៤ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងរ៉ែ និងថាមពល ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **អ៊ឹង អៀង** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ២-លោកស្រី **រឿន សុវណ្ណានី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៣-លោក **សួស សំណាល** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៤-លោក **ទី ពុទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៥-លោក **ជា ឆេង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៦-លោក **សុខ ពិសិដ្ឋ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |

៧-លោក **ពន្លក ផល្លា** ពីវរមន្ត្រី ថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២

៨-លោក **ប៉ុន ប៊ុនធឿន** ពីវរមន្ត្រី ថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២

៩-លោក **ស្អួស រាហ៍មារ៍** ពីវរមន្ត្រី ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

១០-លោក **មាស ដារ៉េត** ពីវរមន្ត្រី ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

១១-លោក **ហ៊ឹម ថៃ** ពីវរមន្ត្រី ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

១២-លោក **កែន ដាលីន** ពីវរមន្ត្រី ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

១៣-លោក **អ៊ុំខ ឌីម៉ូឡា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

១៤-លោក **ឈួន សម្បត្តិរតនៈ** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

១៥-លោក **ព្រួ ម៉ិនឡាយ** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

១៦-លោក **កែវ សុខា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

១៧-លោក **អុល រត្ននា** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

១៨-លោក **ព្រុំ សំអុន** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

១៩-លោក **ម៉ិន ថេត** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

២០-លោក **ស្អួន ម៉ិនសៃ** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

២១-លោក **សែត សៀរ** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

២២-លោក **លី រដ្ឋារិទ្ធ** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ មកជា ថ្នាក់លេខ ២

២៣-លោក **ឃួន រ៉ាស៊ី** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ មកជា ថ្នាក់លេខ ៣

២៤-លោក **គង់ ស៊ីថា** ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១ មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧ កើត ខែ ផល្គុន ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៩.អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ២០២១ ដល់មន្ត្រីរាជការចំនួន ១០១ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងផែនការ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក **នុត សុខសៅរឿន** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ២-លោក **ម៉ុន ចាន់តារា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៣-លោកស្រី **អ៊ឹម សុធា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៤-លោក **ហ៊ាង សុវិទ្យា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |

| | | |
|---|---|---|
| ៥-លោក **អ៊ូ សុខា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៦-លោក **លឹម លីឆេង** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៧-លោក **សែម ស៊ីម៉ានិត** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៨-លោក **ណាន សុត្ថារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៩-លោក **អ៊ុយ សាម៉ន** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១០-លោក **ទ៊ុន ធី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១១-លោក **គឹម ចន្ថាឬទ្ធិ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១២-លោក **ពេជ ពោធិ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១៣-លោក **សូ តូនែរ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ១៤-ឯកឧត្តម **ម៉ន តារៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៥-លោក **គង់ ច័ន្ទណា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៦-លោកស្រី **រស់ ចន្ទូ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៧-លោកស្រី **ឃឹម សាណែត** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៨-លោកស្រី **ខិន សាចត្ថារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៩-លោក **ម៉េង ហ្គួយឃាង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២០-លោក **ជ័យ ណាត** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២១-លោក **គង់ មុន្នី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២២-លោកស្រី **ម៉ែន សុភាព** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៣-លោក **លី ដាវីន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៤-លោកស្រី **អ៊ឹម សុក្រដាវី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៥-លោកស្រី **ច័ន្ទ លក្ខិណា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៦-លោកស្រី **ជួន សេរីរ័ត្ន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៧-លោក **ជា គុង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៨-លោក **អ៊ុន សាវិន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២៩-លោក **ឯម សំអ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៣០-លោកស្រី **ភួង វេជ្ជនី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៣១-លោក **ម៉ម ឆវីរៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៣២-លោក **ហុង សុភា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៣៣-លោក **ហុក ណារិន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៣៤-លោក **តុង បញ្ញាវ័ន្ត** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៣៥-លោក **យ៉េង ប្រុស** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៣៦-លោក **ឡួន ស៊ីលួត** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |

| | | |
|---|---|---|
| ៣៧-លោក **ជឹម សុជាតិ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣៨-លោក **បេត ណារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣៩-លោក **សេង សុវណ្ណាង** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤០-លោក **វ៉ាន់ ម៉ូលីកា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤១-លោកស្រី **ស៊ី វ៉ាន់ណែត** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤២-លោកស្រី **ហ៊ុន ផានី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤៣-លោកស្រី **តាត សុជាតា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤៤-លោក **សោម ច័ន្ទដារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤៥-លោក **សេង អ៊ិត** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤៦-លោកស្រី **ឈុន លក្ខិណា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤៧-លោក **ឡេង ឃាង** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤៨-លោក **ឡុង ខៃត** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៤៩-លោក **សាត រុន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៥០-លោក **ហ៊ាន ញូញៀម** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៥១-លោក **ដូ ប៉េងអាន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៥២-លោក **ហាង្យ វាសនា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៥៣-លោក **ឆាំង ជីវ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៥៤-លោក **គ្រី សុភាព** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៥៥-លោកស្រី **សុខ សុវណ្ណា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៥៦-លោក **អែម សំបុង** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៥៧-លោក **ម៉ុក សេង** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៥៨-លោក **ឃឹម ច័ន្ទរិទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៥៩-លោកស្រី **ផង់ វល័ក្ខ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៦០-លោកស្រី **ណុំ បុប្ផា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៦១-លោក **ម៉ាក់ រ៉ាវុធ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៦២-លោកស្រី **ស្រ៊ិន សុខអូន** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៦៣-លោក **ស៊ាង រិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៦៤-លោក **ហេង ឧត្តម** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៦៥-លោក **ហុក វន្ធា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៦៦-លោក **ហ៊ើរ គីនី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៦៧-លោក **វ៉ាន់ ម៉េន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៦៨-លោក **ឡុង ឡុក** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |

| | | |
|---|---|---|
| ៦៩-លោក **សរ យ៉េង** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧០-លោក **សារ៉ាត់ ពុធនីរ៉ូ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧១-លោក **ផល ចន្ទតិរក្ស** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧២-លោកស្រី **លី ឆុំឆវី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧៣-លោក **ឌួន ភាព** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧៤-លោក **អ៊ូ សុផែន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧៥-លោកស្រី **អ៊ុំ ផារី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧៦-លោកស្រី **ក្រៀល ធីណា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧៧-លោកស្រី **ទូច កេសរ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧៨-លោកស្រី **ណុន ធីតា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧៩-លោកស្រី **អ៊ុក ស៊ីណាន់** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨០-លោក **ណូយ ឧត្តី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨១-លោកស្រី **ឡេង សុត្ថនា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨២-លោក **ហេង ណារី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៣-លោក **ម៉ុំ សត្យា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៤-លោក **គួង ច័ន្ទរចនា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៥-លោក **លាង ហួរ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៦-លោក **ឌួន ណោ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៧-លោក **ថិន មករា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៨-លោក **ទ្រឿង សំណាង** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៩-លោក **ចេង សុភាព** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩០-លោក **ស៊ូ សុហ៊ីន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩១-លោក **អ៊ុន ចំរើន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩២-លោក **ហួរ គីមហៀង** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៣-លោក **គិត តាំងអេង** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៤-លោក **ជា សុភាព** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៥-លោកស្រី **សរ សុគន្ធ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៦-លោក **សួរ សំណាង** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៧-លោក **សិន ឡូ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៨-លោក **គោគ សុខេន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៩-លោក **ពេជ ផុន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |

១០០-លោក **សួន វ៉េង** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

១០១-លោក **អ៊ុច ចំណាប់** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកជាវរមន្ត្រី ថ្នាក់លេខ ៤

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧ កើត ខែ ផល្គុន ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***អន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤០.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ ២០២១ ដល់មន្ត្រីរាជការចំនួន ៤៩ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោកស្រី **ព្រំ សុភាព** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ២-លោកស្រី **ម៉ុំ ចាន់ដានី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៣-លោក **ណុប ម៉ិនធឿន** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៤-ឯកឧត្តម **ហ្សត សារិល** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៥-លោក **ថូ ម៉ិនធី** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |

| | | |
|---|---|---|
| ៦-លោក **ឈុន ផូយ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកជា ថ្នាក់លេខ ១ |
| ៧-លោក **ហុក លី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៨-លោក **ពេជ សេរី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ៩-លោកស្រី **ឡូន អាស្ការីន** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១០-លោក **ចាន់សែន សុវណ្ណនាថ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១១-លោក **ឃឹម លីមុត្រី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១២-លោក **ធឹម បូរាណា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៣-លោក **ហុក វិចិត្រ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៤-លោក **យូ សុភ័ក្រ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៥-លោក **ម៉ន រ៉ាន់** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៦-លោក **រិន ណារិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៧-លោក **ព្រុំ រ៉ូម៉ាំង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៨-លោកស្រី **ផាណា ម៉ុនីដា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ១៩-លោក **ទូ សុខា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២០-លោក **សេក មុនី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកជា ថ្នាក់លេខ ២ |
| ២១-លោកស្រី **សាន សុភាព** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ២២-លោក **តុន ម៉ាច** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ២៣-លោកស្រី **គង់ សារ៉េត** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ២៤-លោក **ឌីន បូរី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ២៥-លោកស្រី **អ៊ុង វណ្ណសិទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ២៦-លោក **ស៊ុយ សុភ័ក្រ្តវិបុល** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ២៧-លោក **ព្រាប រតនា** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ២៨-លោក **សិទ្ធ សិទ្ធី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ២៩-លោក **លឹម ដាណា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៣០-លោក **អ៊ុង កេននធី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៣១-លោកស្រី **ឡូន ម៉ាណាន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៣២-លោក **សុខ ប៊ុន** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៣៣-លោក **វង្ស តារៈ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៣៤-លោក **ឈិត ប៊ុណ្ណារិទ្ធ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៣៥-លោកស្រី **ហៀក ម៉ូរីណា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៣៦-លោក **សំ ចាន់ធី** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៣៧-លោក **ហ៊ាង ខៃឡាយ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |

| | | |
|---|---|---|
| ៣៨-លោក **យន សុមេធ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៣៩-លោកស្រី **សយ សុតា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៤០-លោកស្រី **ញឹម ចាន់ដារ៉ា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៤១-លោក **សាំង សុទ្ធារ៉ា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៤២-លោក **ឡាយ សារិទ្ធ** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ៤៣-លោកស្រី **ជន ម៉ាលីនដា** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
